ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# កម្មវិធីសិក្សាលម្អិត

មុខវិជ្ជា

# រូបវិទ្យា

បណ្ដុំវិទ្យាសាស្ត្រ

សម្រាប់

## កម្រិតមធ្យមសិក្សាទុតិយភូមិ

២០១៨

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥០៤ **អយក.**ប្រក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជា កម្រិតមធ្យមសិក្សាទុតិយភូមិ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញប្រកាសលេខ៣០២ អយក.ប្រក ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស
- តាមសំណើរបស់គណៈកម្មការនិងអនុគណៈកម្មការកែលម្អកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល

## សម្រេច

**ប្រការ១ .-**

ប្រកាសដាក់ឱ្យប្រើជាផ្លូវការ "**កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតមធ្យមសិក្សាទុតិយភូមិ**" ។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

**ប្រការ២ .-**

កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតមធ្យមសិក្សាទុតិយភូមិនេះ មានមាតិកាសំខាន់ៗ ដូចខាងក្រោម៖

- សេចក្តីផ្តើម
- គោលបំណង
- គោលគំនិតសំខាន់ៗ
- របាយម៉ោងសិក្សា
- ការណែនាំអនុវត្ត
- ការវាយតម្លៃ
- តារាងកម្មវិធីសិក្សា

ខ្លឹមសារលម្អិតនៃកម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតមធ្យមសិក្សាទុតិយភូមិជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣ .-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ និងអ្នកពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៧កើត ខែ ស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួង អយក
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ អគ.អរ

# បុព្វកថា

ការអប់រំជាវិស័យគន្លឹះមួយក្នុងការរួមចំណែកអភិវឌ្ឍធនធានមនុស្ស សំដៅជំរុញឱ្យសង្គមនិងសេដ្ឋកិច្ចរីកចម្រើន។ បច្ចុប្បន្ននេះ សង្គមនិងសេដ្ឋកិច្ចមានការអភិវឌ្ឍនិងការរីកចម្រើនដែលជាកម្លាំងចលករជំរុញឱ្យមានការកែលម្អការអប់រំ ដើម្បីអាចឆ្លើយតបទៅនឹងការវិវត្តថ្មីៗរបស់សង្គមនិងសេដ្ឋកិច្ច។ ប៉ុន្មានទសវត្សរ៍ចុងក្រោយនៃសតវត្សរ៍ទី២០និងដើមសតវត្សរ៍ទី២១នេះ សង្គមនិងសេដ្ឋកិច្ចឈានដល់បរិបទថ្មីដែលមិនធ្លាប់មានកន្លងមកដោយពិភពលោកកាន់តែបើកចំហ ការប្រកួតប្រជែងកាន់តែស្រួចស្រាល់ជាងមុន វិស័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រកាន់តែទំនើបនិងប្រសើរឡើង។ កត្តាទាំងនេះនាំឱ្យប្រទេសឬជាតិសាសន៍នានាខិតខំពង្រឹងធនធានមនុស្សរបស់ខ្លួន ដើម្បីតាមឱ្យទាន់និងអាចឈរជើងប្រកបដោយឧត្តមភាពក្នុងបរិបទថ្មីនៃសង្គមនិងសេដ្ឋកិច្ចរបស់ពិភពលោក។

ដើម្បីឆ្លើយតបនឹងតម្រូវការរីកចម្រើនរបស់សង្គមនិងសេដ្ឋកិច្ចថ្មី ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវការកែទម្រង់កម្មវិធីសិក្សាអប់រំចំណេះទូទៅដែលជាមូលដ្ឋានសម្រាប់ឱ្យអ្នកសិក្សាអាចបន្តការសិក្សា និងទទួលការបណ្តុះបណ្តាលផ្សេងៗទៀត សំដៅលើកកម្ពស់គុណភាពធនធានមនុស្សប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា ដែលជាធាតុសំខាន់ក្នុងកម្មវិធីសិក្សា។ កម្មវិធីសិក្សាលម្អិតនេះចែកជាបីភូមិសិក្សាដាច់ដោយឡែកពីគ្នាតែប្រទាក់ក្រឡានិងគាំទ្រគ្នា។ កម្មវិធីសិក្សាលម្អិតកម្រិតមធ្យមសិក្សាទុតិយភូមិនេះ បានបន្ថែមម៉ោងសិក្សាច្រើនជាងមុនទៅក្នុងកម្មវិធីសិក្សា។ ការកែទម្រង់កម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ សំដៅកសាងមូលដ្ឋានគ្រឹះសម្រាប់ការអប់រំនៅកម្រិតបន្តដោយពង្រីកវិសាលភាពចំណេះដឹង បំណិនការអប់រំសីលធម៌ គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាព ព្រមទាំងផ្តល់នូវចំណេះដឹងមូលដ្ឋានផ្នែកបច្ចេកវិទ្យា បំណិនសតវត្សរ៍ទី២១ និងបំណិនសិក្សាពេញមួយជីវិត ដើម្បីឱ្យក្លាយខ្លួនជាបុគ្គលល្អដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។

ក្រសួង សង្ឃឹមយ៉ាងមុតមាំថា កម្មវិធីសិក្សាលម្អិតនេះនឹងបម្រើជាប្រយោជន៍ដ៏មានប្រសិទ្ធភាពក្នុងការអភិវឌ្ឍសៀវភៅសិក្សាគោល សម្ភារៈឧបទេស ឯកសារជំនួយនានាក្នុងការរៀននិងបង្រៀន និងឧបករណ៍ពិនិត្យតាមដាន វាយតម្លៃផ្សេងៗ។

ក្រសួង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអនុគណៈកម្មការមុខវិជ្ជាឯកទេសទាំងអស់ លេខាធិការដ្ឋានកែលម្អកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមនិងដើរតួនាទីស្នូលក្នុងការសម្របសម្រួល ព្រមទាំងដឹកនាំរៀបចំតាក់តែងកម្មវិធីសិក្សាលម្អិតនេះឱ្យបានសម្រេចជាផ្លែផ្កាឡើងនាពេលនេះ។

ថ្ងៃ អង្គារ ៧រោច ខែ ភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ តុលា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

# អារម្ភកថា

យោងលើកំណែទម្រង់ជម្រៅក្នុងវិស័យអប់រំដើម្បីអភិវឌ្ឍធនធានមនុស្សប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដែលជាកត្តាកំណត់ភាពជោគជ័យនៃការអភិវឌ្ឍលើវិស័យនានា និងដើម្បីតម្រង់ទិសសិស្សនាបច្ចុប្បន្នទៅតាមតម្រូវការទីផ្សារការងារ ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតលេខាធិការដ្ឋានសម្រាប់សម្រួលការងារអភិវឌ្ឍក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេសនេះឡើងដោយមានអនុគណៈកម្មការតាមមុខវិជ្ជានីមួយៗ។ ក្នុងក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេសដែលបានអភិវឌ្ឍរួចមកហើយនោះក៏មានញែកចេញជាពីរបណ្តុំនៃមុខវិជ្ជាវិទ្យាសាស្ត្រ គឺបណ្តុំវិទ្យាសាស្ត្រ និងបណ្តុំវិទ្យាសាស្ត្រសង្គម។ ដើម្បីឱ្យការអនុវត្តក្របខណ្ឌកម្មវិធីសិក្សានេះបានជោគជ័យប្រកបដោយប្រសិទ្ធភាព អនុគណៈកម្មការរូបវិទ្យាក៏បានរៀបចំចងក្រងកម្មវិធីសិក្សាលម្អិតសម្រាប់កម្រិតមធ្យមសិក្សាទុតិយភូមិដោយអនុលោមទៅតាមការកំណត់នៃក្របខណ្ឌកម្មវិធីសិក្សាខាងលើ។

ឯកសារនេះបានបង្ហាញពីចំណុចសំខាន់ៗរួមមាន គោលបំណងនៃការសិក្សារូបវិទ្យានៅកម្រិតមធ្យមសិក្សាទុតិយភូមិ ផ្នែកបណ្តុំវិទ្យាសាស្ត្រ ខ្លឹមសារសំខាន់ៗ លទ្ធផលរំពឹងទុក របាយម៉ោងសិក្សា ការណែនាំអនុវត្តវិធីសាស្ត្របង្រៀន ការវាយតម្លៃ និងតារាងកម្មវិធីសិក្សា។ នៅពេលរៀនចប់កម្រិតមធ្យមសិក្សាទុតិយភូមិបណ្តុំវិទ្យាសាស្ត្រនេះ សិស្សនឹងទទួលបានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាទាំងអស់នេះដើម្បីជាគ្រឹះសម្រាប់បន្តការសិក្សាទៅកម្រិតឧត្តមសិក្សាឬចូលសាលាអប់រំបច្ចេកទេស និងជាមធ្យោបាយសម្រាប់អនុវត្តក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

អនុគណៈកម្មការមុខវិជ្ជាឯកទេសរូបវិទ្យា មានជំនឿយ៉ាងមុតមាំថា កម្មវិធីសិក្សាលម្អិតមុខវិជ្ជារូបវិទ្យាបណ្តុំវិទ្យាសាស្ត្រកម្រិតមធ្យមសិក្សាទុតិយភូមិនេះនឹងបម្រើឱ្យការអភិវឌ្ឍធនធានមនុស្សជាចម្បងនិងមានប្រសិទ្ធភាពក្នុងការអនុវត្តទូទាំងព្រះរាជាណាចក្រកម្ពុជា។

**អនុគណៈកម្មការមុខវិជ្ជាឯកទេសរូបវិទ្យា**

# មាតិកា


ប្រកាស ........ i

បុព្វកថា ........ iii

អារម្ភកថា ........ iv

មាតិកា ........ v

១- សេចក្តីផ្តើម ........ 1

២- គោលបំណង ........ 2

៣- គោលគំនិតៗសំខាន់ៗ ........ 2

៤- របាយម៉ោងសិក្សា ........ 3

៥- ការណែនាំអនុវត្ត ........ 3

៦- ការវាយតម្លៃ ........ 4

៧- តារាងកម្មវិធីសិក្សា ........ 5

៧.១- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១០ ........ 5

៧.២- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១១ ........ 12

៧.៣- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១២ ........ 20

៨- ឯកសារយោង ........ 34

៩- បញ្ជីឈ្មោះគណៈកម្មការ ........ 35

## ១- សេចក្តីផ្តើម

នៅប្រទេសកម្ពុជាយើង កម្មវិធីសិក្សាជាតិបានអភិវឌ្ឍ៤ដំណាក់កាលរួចមកហើយ រីឯក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេសនេះ ជាដំណាក់កាលទី៥នៃការអភិវឌ្ឍកម្មវិធីសិក្សាជាតិ។

លទ្ធផលនៃការសិក្សាស្រាវជ្រាវលើកម្មវិធីសិក្សា និងការវិភាគសៀវភៅសិក្សាគោលដែលកំពុងប្រើប្រាស់នាពេលបច្ចុប្បន្នបានបង្ហាញពីភាពចាំបាច់ដែលត្រូវកែលម្អលើខ្លឹមសារមេរៀន ភាពពាក់ព័ន្ធពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយទៀតតាមលំដាប់លំដោយ និងគ្រប់ជ្រុងជ្រោយ។ ជាពិសេសមុខវិជ្ជាគណិតវិទ្យា និងរូបវិទ្យានៅក្នុងកម្មវិធីសិក្សាចំណេះទូទៅត្រូវឱ្យមានការពាក់ព័ន្ធគ្នាទៅនឹងការអនុវត្តជាក់ស្តែងក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងការវិវត្តរបស់ពិភពលោក។

ដូច្នេះកម្មវិធីសិក្សាលម្អិតមុខវិជ្ជារូបវិទ្យាបណ្តុំវិទ្យាសាស្ត្រកម្រិតមធ្យមសិក្សាទុតិយភូមិថ្មីនេះ ត្រូវបានអភិវឌ្ឍឡើងដោយផ្អែកលើក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស និងកម្មវិធីសិក្សានៃបណ្តាប្រទេសក្នុងសហគមន៍អាស៊ានមួយចំនួនដូចជា ប្រទេសសិង្ហបុរី ប្រទេសម៉ាឡេស៊ី ប្រទេសថៃជាដើម។

ចំណុចសំខាន់ៗដែលត្រូវបានកែសម្រួល និងបន្ថែមលើកម្មវិធីសក្សាវិទ្យាសាស្ត្រឆ្នាំ២០០៦រួមមាន៖

- កែសម្រួលខ្លឹមសារមេរៀន ដោយរៀបតាមលំដាប់លំដោយនៃមេរៀនឱ្យមានភាពប្រទាក់ក្រឡាគ្នាពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២
- បន្ថែមម៉ោងសិក្សា៖
  - ○ថ្នាក់ទី១០ ត្រូវបានប្តូរចំនួនម៉ោងសិក្សាពី២ម៉ោង ទៅ៤ម៉ោងវិញ ក្នុង១សប្តាហ៍
  - ○ថ្នាក់ទី១១និងថ្នាក់ទី១២ ត្រូវបានប្តូរម៉ោងសិក្សាពី៣ម៉ោង ទៅ៤ម៉ោងវិញ ក្នុង១សប្តាហ៍។
- តារាងខ្លឹមសារលម្អិត ត្រូវបានរៀបចំឡើងវិញ
- លទ្ធផលរំពឹងទុកតាមកម្រិតថ្នាក់ ត្រូវបានរៀបចំឡើងវិញ
- រៀបចំទម្រង់នៃប្រព័ន្ធអប់រំថ្មីតាមរចនាសម្ព័ន្ធដែលសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិថ្នាក់ទី១០ មានជម្រើស៣បណ្តុំគឺ បណ្តុំវិទ្យាសាស្ត្រ បណ្តុំវិទ្យាសាស្ត្រសង្គម និងអប់រំបច្ចេកទេសនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយអនុលោមទៅតាមក្របខណ្ឌគុណវុឌ្ឍិជាតិ
- បញ្ចូលវិធីសាស្ត្រការរៀន និងបង្រៀនតាមបែបអិរក (IBL) និងការរៀននិងបង្រៀនតាមបែបគោលវិធីស្ទែម ដែលជាវិធីសាស្ត្រក្នុងសតវត្សរ៍ទី២១
- ញែកចេញពីមុខវិជ្ជាវិទ្យាសាស្ត្រ ទៅជាមុខវិជ្ជាមួយៗដាច់ដោយឡែកពីគ្នា
- ផ្តាច់ចេញពីគ្នារវាងបណ្តុំវិទ្យាសាស្ត្រ និងបណ្តុំវិទ្យាសាស្ត្រសង្គម។

ក្នុងដំណើរការអភិវឌ្ឍកម្មវិធីសិក្សាលម្អិតមុខវិជ្ជារូបវិទ្យាថ្មីនេះ មានការពិគ្រោះយោបល់យ៉ាងល្អិតល្អន់និងច្រើនលើកច្រើនសារ តាមរូបភាពប្រជុំក្រុមការងារសិក្ខាសាលាពិគ្រោះយោបល់ដែលមាននាយកដ្ឋានពាក់ព័ន្ធ សកលវិទ្យាល័យភូមិន្ទភ្នំពេញ និងដៃគូអភិវឌ្ឍនានា។

អនុគណៈកម្មការយើងខ្ញុំសង្ឃឹមថា កម្មវិធីសិក្សាលម្អិតថ្មីនេះ នឹងផ្តល់ឱ្យអ្នកសិក្សាទទួលបាននូវវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា ជាមូលដ្ឋានគ្រឹះដើម្បីប្រើប្រាស់គ្រប់ស្ថានភាពរស់នៅក្នុងសង្គម និងលទ្ធភាពក្នុងការចូលរួមអភិវឌ្ឍប្រទេសជាតិប្រកបដោយគុណភាព។

## ២- គោលបំណង

ការសិក្សាវិទ្យាសាស្ត្រផ្នែករូបវិទ្យានៅមធ្យមសិក្សាទុតិយភូមិមានបំណងបណ្ដុះបណ្ដាលអ្នកសិក្សាឱ្យ៖

- ទទួលបានវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទារឹងមាំដើម្បីបន្តការសិក្សាទៅថ្នាក់ឧត្តម ឬចូលបម្រើក្នុងវិស័យផ្សេងៗទៀតតាមតម្រូវការទីផ្សារការងារក្នុងសតវត្សរ៍ទី២១
- បង្កើនសមត្ថភាព គិត ពិសោធ វិភាគ សំយោគ ដោះស្រាយបញ្ហា និងសិក្សាស្រាវជ្រាវ
- អនុវត្តវិធីវិទ្យាសាស្ត្រក្នុងការដោះស្រាយបញ្ហាទាក់ទងនឹងវិទ្យាសាស្ត្រ និងបង្កើនសមត្ថភាពក្នុងការប្រើប្រាស់ឧបករណ៍វិទ្យាសាស្ត្រប្រកបដោយសុវត្ថិភាព និងភាពវិជ្ជមាន
- អភិវឌ្ឍកោសល្យ និងសមត្ថភាព ដើម្បីក្លាយខ្លួនជាអ្នកជំនាញបច្ចេកទេសប្រកបដោយប្រាជ្ញាស្មារតី សញ្ចេតនា និងរាងកាយរឹងមាំ
- បណ្ដុះស្មារតីលើការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រដើម្បីក្លាយខ្លួនជាអ្នកវិទ្យាសាស្ត្រ
- លើកកម្ពស់ស្មារតីក្នុងកាត់បន្ថយអបិយជំនឿដែលមិនមានលក្ខណៈវិទ្យាសាស្ត្រ។

**ទស្សនវិជ្ជានៃការអប់រំវិទ្យាសាស្ត្រ**

ការអប់រំវិទ្យាសាស្ត្ររូបវិទ្យាមានទស្សនៈ៖

- បង្កើនការស្រូបយកចំណេះដឹងផ្នែកវិទ្យាស្ត្រដើម្បីកាត់បន្ថយអបិយជំនឿមិនសមហេតុផល
- បង្កើនសមត្ថភាពសង្កេត ពិសោធ និងដោះស្រាយបញ្ហាតាមរយៈចំណេះដឹង និងបំណិននៃការអនុវត្តក្នុងការសិក្សាកន្លងមក
- អភិវឌ្ឍចំណេះដឹង និងបំណិនស្របទៅនឹងជំនាញសតវត្សរ៍ទី២១ដែលជាតម្រូវការសកលលោក
- ពង្រឹងការវិវិទ្ធិថ្ម័យពីទំនាក់ទំនងរវាងវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ដល់ពលរដ្ឋគ្រប់រូប
- ពង្រឹងគុណតម្លៃ និងគុណធម៌ដល់មនុស្សគ្រប់រូបឱ្យសមស្របនឹងតម្លៃនៃអ្នកវិទ្យាសាស្ត្រ
- បង្កើនស្មារតីយកចិត្តទុកដាក់ស្រាវជ្រាវលើមុខវិជ្ជាវិទ្យាសាស្ត្រដើម្បីត្រៀមខ្លួនក្លាយជាវិស្វករបច្ចេកវិទ្យា ឬជាអ្នកវិទ្យាសាស្ត្រ។

## ៣- គោលគំនិតសំខាន់ៗ

មុខវិជ្ជារូបវិទ្យានៅកម្រិតមធ្យមសិក្សាទុតិយភូមិចែកចេញជាផ្នែកធំៗគឺ៖

- មេកានិច
- ទែម៉ូឌីណាមិច
- អគ្គិសនី និងម៉ាញេទិច
- អុបទិច
- រលក
- រូបវិទ្យាទំនើប។

## ៤- របាយម៉ោងសិក្សា

របាយម៉ោងសិក្សាមុខវិជ្ជារូបវិទ្យាកម្រិតមធ្យមសិក្សាទុតិយភូមិបានបែងចែកដូចក្នុងតារាងខាងក្រោម៖

| ថ្នាក់ទី | ម៉ោងសិក្សា |
|---|---|
| ១០ | ៤ម៉ោង x ៣៥សប្តាហ៍ = ១៤០ម៉ោង/ឆ្នាំសិក្សា (៤ម៉ោងសិក្សា/សប្តាហ៍) |
| ១១ | ៤ម៉ោង x ៣៥សប្តាហ៍ = ១៤០ម៉ោង/ឆ្នាំសិក្សា (៤ម៉ោងសិក្សា/សប្តាហ៍) |
| ១២ | ៤ម៉ោង x ៣៥សប្តាហ៍ = ១៤០ម៉ោង/ឆ្នាំសិក្សា (៤ម៉ោងសិក្សា/សប្តាហ៍) |

បញ្ជាក់៖ ១ម៉ោងសិក្សាស្មើនឹង៥០នាទី។

## ៥- ការណែនាំអនុវត្ត

ដើម្បីសម្រេចគោលបំណង និងធ្វើឱ្យការអនុវត្តកម្មវិធីសិក្សារូបវិទ្យាមធ្យមសិក្សាទុតិយភូមិបណ្តុំវិទ្យាសាស្ត្រឱ្យទទួលបានជោគជ័យគ្រូត្រូវ៖

- រៀបចំកិច្ចតែងការបង្រៀនឱ្យបានត្រឹមត្រូវតាមគោលការណ៍ និងសកម្មភាពច្បាស់លាស់នៃមេរៀននីមួយៗ។ ក្នុងការរៀបចំកិច្ចតែងការបង្រៀន គ្រូត្រូវគោរពតាមប្រាំជំហានរួមមាន រដ្ឋបាលថ្នាក់ រំលឹកមេរៀនចាស់ បង្រៀនមេរៀនថ្មី ពង្រឹងពុទ្ធិ និងដាក់កិច្ចការឱ្យសិស្ស ឬណែនាំសិស្សឱ្យស្វ័យសិក្សាមេរៀនបន្ត។
- ផ្តល់បទពិសោធផ្សេងៗដើម្បីឱ្យសិស្សអាចស្វែងយល់ និងចេះរៀនដោយខ្លួនឯងគឺគ្រូគ្រាន់តែជាអ្នកណែនាំសិស្សក្នុងការរៀនរូបវិទ្យា ហើយជាអ្នកសម្របសម្រួលនៅពេលសិស្សជួបបញ្ហាស្មុគស្មាញ ដោយចៀសវាងការផ្ទេរចំណេះដឹងដល់សិស្សតាមបែបគ្រូមជ្ឈមណ្ឌល។
- រៀបចំមេរៀនឱ្យទាក់ទងគ្នា រំលឹកសាចុះសាឡើង។ វាយតម្លៃ និងបំពេញចំណុចខ្វះខាតរបស់សិស្ស។ គ្រូប្រើសំណួរបំផុសដើម្បីសួរសិស្ស រួចកត់ត្រានូវចម្លើយរបស់សិស្ស បន្ទាប់មកត្រូវវាយតម្លៃនូវចម្លើយទាំងនោះ។
- ផ្សារភ្ជាប់ចំណេះដឹងផ្នែកទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។
- ដឹកនាំសិស្សឱ្យយល់ដឹងពីវិធីវិទ្យាសាស្ត្រ និងគោលវិធីស្វែម។
- ដឹកនាំសិស្សធ្វើពិសោធន៍ និងស្រាវជ្រាវតាមបែបគោលវិធីស្វែម។
- យកចិត្តទុកដាក់ក្នុងការរៀននិងបង្រៀនប្រកបដោយក្រមសីលធម៌។
- ធ្វើសកម្មភាពឱ្យស្របតាមស្ថានភាពរស់នៅរបស់សិស្សដែលស្ថិតក្នុងបរិបទជីវភាពវប្បធម៌ខ្មែរនិងតថភាពជាក់ស្តែងនៃជីវិតប្រចាំថ្ងៃ។
- ជ្រើសរើសសម្ភារៈឧបទ្ទេសងាយៗក្នុងស្រុកដែលមានតាមមូលដ្ឋានជាក់ស្តែងមកច្នៃប្រឌិតសម្រាប់ការបង្រៀនរូបវិទ្យា។
- បណ្តុះស្មារតីអ្នកសិក្សាឱ្យចេះដោះស្រាយបញ្ហាជាក់ស្តែង ដើម្បីឱ្យពួកគេមានការចងចាំរាល់ខ្លឹមសារសំខាន់ៗនៃមេរៀនបានយូរ។

### វិធីសាស្ត្របង្រៀន

- នៅមធ្យមសិក្សាទុតិយភូមិ ការបង្រៀនរូបវិទ្យាមានលក្ខណៈតាមបែបវិធីវិទ្យាសាស្ត្រជាងនៅមធ្យមសិក្សាបឋមភូមិ។ គ្រូអាចផ្តល់បញ្ញត្តិរូបវិទ្យាដល់អ្នកសិក្សាមិនត្រឹមតែតាមរយៈឧទាហរណ៍ តាមការបកស្រាយ ឬតាមនិយមន័យលើក្តារខៀនប៉ុណ្ណោះទេ ប៉ុន្តែក៏អាចផ្តល់បញ្ញត្តិទាំងនេះតាមរយៈគេហទំព័រការសិក្សាស្រាវជ្រាវស្វែងយល់បន្ថែមទៀតរបស់ពួកគេផងដែរ

- ក្នុងការបណ្តុះបញ្ញត្តិដល់សិស្ស គ្រូអាចប្រើវិធីសាស្ត្រសិស្សមជ្ឈមណ្ឌលដែលមានយុទ្ធវិធីតាមបែបរិះរក គឺសង្កត់ធ្ងន់ទៅលើការរៀនតាមរយៈសកម្មភាពអនុវត្តដែលជំរុញឱ្យសិស្សមានការងឿងឆ្ងល់ ចង់ចេះ ចង់ដឹងទៅលើបញ្ហា និងព្យាយាមរកដំណោះស្រាយរបស់គេ
- តាមបែបស្ថាបនា យុទ្ធវិធីនេះជួយពង្រឹងបន្ថែមទៅលើយុទ្ធវិធីតាមបែបរិះរក គឺការយល់ដឹងរបស់អ្នកសិក្សាផ្តើមចេញពីបទពិសោធរបស់ពួកគេ។ ក្នុងការរៀនតាមបែបស្ថាបនា គ្រូជាអ្នកសម្របសម្រួលដោយបង្កើតបរិបទពិសោធឱ្យសិស្សសង្កេត និងសន្និដ្ឋាន។

វិធីសាស្ត្រនេះមានប្រយោជន៍ណាស់ ប៉ុន្តែបើគ្រូមិនបានប្រើវាឱ្យចំគោលដៅ និងត្រឹមត្រូវទេ វាអាចនឹងធ្វើឱ្យការបង្រៀនមានភាពត្រឡប់ត្រឡិនមិនច្បាស់លាស់។ ដូច្នេះនៅពេលប្រើប្រាស់វិធីសាស្ត្រនេះគ្រូត្រូវ៖

- កំណត់គោលដៅមេរៀនឱ្យបានច្បាស់លាស់ហើយស្របនឹងអ្វីដែលសិស្សគួរទទួលបាន
- ប្រាស្រ័យទាក់ទងជាមួយសិស្ស និងណែនាំពួកគេឱ្យបានត្រឹមត្រូវដោយធ្វើយ៉ាងណាឱ្យប្រាកដថាពួកគេយល់អំពីគោលបំណងនៃមេរៀន
- រៀបចំកិច្ចការសិស្សឱ្យមានរបៀប និងមានវគ្គស្មើត្រឹមត្រូវកម្រិតខ្លឹមសារមេរៀនពីងាយទៅពិបាកដែលជាកត្តាធ្វើឱ្យសិស្សជក់ចិត្តក្នុងការអនុវត្តលំហាត់ពីមួយទៅមួយ និងបានយល់ច្បាស់ពីមេរៀន
- ផ្តល់យោបល់ដើម្បីត្រួសត្រាយនូវគំនិតរបស់សិស្សឱ្យឈានដល់ចំណុចដែលចង់បាន។

## ៦- ការវាយតម្លៃ

### ៦.១- វិធីវាយតម្លៃ

ក្នុងការវាយតម្លៃគេប្រើវិធីសំខាន់ៗពីរ៖

- វង្វាយតម្លៃជាប្រចាំនៅពេលបង្រៀនចប់មេរៀននីមួយៗ។ វង្វាយតម្លៃនេះក៏អនុវត្តតាមកម្រិតប្លូមដែរ គឺវាយតម្លៃទៅលើវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដើម្បីស្ទាបស្ទង់ការយល់ដឹងរបស់សិស្សលើមេរៀនដែលបានរៀនរួចនិងការអនុវត្តថា "តើសិស្សានុសិស្សអនុវត្តបំណិនបានកម្រិតណាហើយមានការផ្លាស់ប្តូរឥរិយាបថដូចម្តេច។ ការធ្វើរបៀបនេះដើម្បីងាយស្រួលក្នុងការបំប៉នសិស្សឱ្យមានលទ្ធភាពរៀនមេរៀនបន្ទាប់ ឬមេរៀនពាក់ព័ន្ធ។ គ្រូត្រូវដកយកបទពិសោធនិងជ្រើសរើសវិធីសាស្ត្រល្អៗមកបង្រៀនសិស្សឱ្យមានប្រសិទ្ធភាព។
- វង្វាយតម្លៃសរុបធ្វើនៅចុងខែនីមួយៗ ឬត្រីមាស ឬឆមាស ដើម្បីវាស់សមត្ថភាព និងវាយតម្លៃលើលទ្ធផលសិក្សាសរុបរបស់សិស្ស។

### ៦.២- រូបភាពវាយតម្លៃ

- សំណួរផ្ទាល់មាត់
- សំណួរសរសេរ
- អនុវត្តលំហាត់ក្នុងរយៈពេលខ្លី (១០-១៥នាទី)
- អនុវត្តលំហាត់ក្នុងរយៈពេលវែង (២០-៥០នាទី)
- ប្រឡងប្រជែងតាមរយៈសកម្មភាពស្ទែម (STEM)
- ការងារគម្រោង។

## ៧- តារាងកម្មវិធីសិក្សា

### ៧.១- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១០ (១សប្ដាហ៍ ៤ម៉ោង ១ឆ្នាំសិក្សា ១៤០ម៉ោង)

វត្ថុបំណងកម្មវិធីលម្អិតថ្នាក់ទី១០ ផ្ដល់ឱ្យសិស្សបន្តពីកម្រិតមូលដ្ឋានផ្នែក៖

#### ១- វិជ្ជាសម្បទា

- **មេកានិច៖** ចលនាត្រង់ ច្បាប់ញូតុន កម្មន្ត ថាមពល និងអានុភាព សម្ពាធនៃសន្ទនីយ៍ស្ដាទិច ជីវិត និងថាមពល
- **ទែម៉ូឌីណាមិច៖** ការរីកនៃអង្គធាតុ កម្ដៅ
- **អគ្គិសនី៖** បន្ទុក និងដែនអគ្គិសនី ប៉ូតង់ស្យែលអគ្គិសនី និងថាមពលប៉ូតង់ស្យែលអគ្គិសនី
- **ម៉ាញេទិច៖** ដែនម៉ាញ៉េទិចនៃចរន្តអគ្គិសនី
- **អុបទិច៖** ចំណាំងផ្លាត និងចំណាំងបែរនៃពន្លឺ កញ្ចក់ និងឡង់ទី។

#### ២- បំណិនសម្បទា

បន្ទាប់ពីទទួលបានចំណេះដឹង សិស្សអាច៖

- ពន្យល់ បកស្រាយ បង្ហាញ និងអនុវត្តតាមផ្នែកនិងមេរៀននីមួយៗបានច្បាស់លាស់
- ធ្វើពិសោធន៍តាមបែបបរិមាណ និងបែបគុណភាពនៃមេរៀននីមួយៗ និងចេះប្រើឧបករណ៍ពិសោធន៍បានត្រឹមត្រូវតាមវិធីវិទ្យាសាស្ត្រ
- ពន្យល់បានច្បាស់នូវបាតុភូតរូបវិទ្យាទាំងក្នុងទ្រឹស្ដី និងក្នុងជីវភាពរស់នៅ
- ឆ្លើយសំណួរបានរហ័សនិងត្រឹមត្រូវតាមទ្រឹស្ដីវិទ្យាសាស្ត្រ
- គណនាលំហាត់បានរហ័សដោយប្រើរូបមន្តបានត្រឹមត្រូវ

#### ៣- ចរិយាសម្បទា

- បណ្ដុះស្មារតីលើសកម្មភាពស្វែម និងផលិតសម្ភារៈឧបទេសងាយៗដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ
- បណ្ដុះស្មារតីសិស្សឱ្យចេះថែរក្សាឧបករណ៍ពិសោធ និងចូលចិត្តការសិក្សាស្រាវជ្រាវ។

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| **ជំពូក១: មេកានិច** | | **៦៦ម៉** |
| **មេរៀនទី១ : ប្រវត្តិរូបវិទ្យា**<br>១.១- តើរូបវិទ្យាជាអ្វី?<br>១.២- បច្ចេកវិទ្យា និងវិទ្យាសាស្ត្រសង្គម<br>១.៣- ធម្មជាតិនៃច្បាប់រូបវិទ្យា<br>១.៤- ទំនាក់ទំនងរវាងគណិតវិទ្យានិងរូបវិទ្យា<br>១.៥- រង្វាស់និងកម្រិតលម្អៀងនៃឧបករណ៍<br>១.៦- លេខមានន័យ<br>១.៧- ទំហំស្កាលែ និងទំហំវ៉ិចទ័រ<br>១.៨- ផលបូកនិងផលដកវ៉ិចទ័រ | **វិជ្ជាសម្បទា**<br>- រៀបរាប់បានក្បោះក្បាយនូវអ្វីដែលហៅថារូបវិទ្យា<br>- រៀបរាប់ពីទំនាក់ទំនងរវាងគណិតវិទ្យានិងរូបវិទ្យា<br>- ប្រាប់ពីភាពខុសគ្នារវាងទំហំស្កាលែ និងទំហំវ៉ិចទ័រ។<br>**បំណិនសម្បទា**<br>- ពន្យល់ច្បាស់នូវលេខមានន័យ<br>- បង្ហាញកុំប៉ូសង់ ឬកូអរដោនេនៃវ៉ិចទ័រមួយតាមអក្ស (អក្សអាប់ស៊ីសនិងអក្សអរដោនេ)<br>- បកស្រាយច្បាស់លាស់នូវកម្រិតលម្អៀង(ប្រៀបធៀបលទ្ធផលរវាងពិសោធន៍និងពិសោធន៍) (Percentage difference) និងកម្រិតលម្អៀងជាភាគរយ | ១០ម៉ |

| | | |
|---|---|---|
| | (Percentage error)<br>(ប្រៀបធៀបតម្លៃពិសោធន៍ជាមួយតម្លៃតាមទ្រឹស្តី)<br>- ញែកនូវភាពខុសគ្នារវាងទំហំវ៉ិចទ័រ និងទំហំស្កាលែ ព្រមទាំងឱ្យឧទាហរណ៍មួយៗ<br>- អនុវត្តទ្រឹស្តីផលបូកវ៉ិចទ័រ (ដោយប្រើ ទ្រឹស្តីបទពីតាគ័រ ទ្រឹស្តីបទធរណីមាត្រ ទ្រឹស្តីបទកូស៊ីនុស)<br>- ធ្វើពិសោធន៍លើរង្វាស់ដើម្បីកំណត់ភាពជាក់លាក់និងកម្រិតលម្អៀងនៃពិសោធន៍ (ដោយប្រើម៉ែត្រប៉ូត និង មីក្រូម៉ែត្រ)។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីប្រុងប្រយត្នក្នុងការធ្វើប្រមាណវិធីនៅក្នុងរូបវិទ្យា។ | |
| **មេរៀនទី២ : ចលនាត្រង់**<br>២.១- តម្រុយ បម្លាស់ទី និងចម្ងាយចរ<br>២.២- វ៉ិចទ័រល្បឿនមធ្យម និងល្បឿនមធ្យម<br>២.៣- វ៉ិចទ័រល្បឿនខណៈ និងល្បឿនខណៈ<br>២.៤- សម្ទុះមធ្យមនិងសម្ទុះខណៈ<br>២.៥- សមីការស៊ីនេទិចនៃល្បឿនថេរ<br>២.៦- សមីការស៊ីនេទិចនៃសម្ទុះថេរ<br>២.៧- ការវិភាគក្រាប(ក្រាបនៃចម្ងាយចរអនុគមន៍នឹងពេល ក្រាបនៃល្បឿនអនុគមន៍នឹងពេល ក្រាបនៃ សម្ទុះអនុគមន៍នឹងពេល)<br>២.៨- ទន្លាក់សេរី | **វិជ្ជាសម្បទា**<br>- ឱ្យនិយមន័យ តម្រុយ ចម្ងាយចរ បម្លាស់ទី និងរូបមន្តឱ្យបានច្បាស់លាស់ព្រមទាំងលើកឧទាហរណ៍<br>- ឱ្យនិយមន័យវ៉ិចទ័រល្បឿននិងល្បឿនមធ្យម<br>- ប្រាប់មេគុណប្រាប់ទិសនៃក្រាបចម្ងាយចរជាអនុគមន៍នៃពេល<br>- ប្រាប់មេគុណប្រាប់ទិសនៃក្រាបល្បឿនជាអនុគមន៍នៃពេល។<br>**បំណិនសម្បទា**<br>- គណនាល្បឿនតាមក្រាបសម្ទុះជាអនុគមន៍នៃពេល<br>- សរសេរសមីការស៊ីនេទិចនៃទន្លាក់សេរី<br>- បកស្រាយសមីការស៊ីនេទិចនៃចលនាត្រង់ស្មើ<br>- បកស្រាយសមីការស៊ីនេទិចនៃចលនាត្រង់ប្រែប្រួលស្មើ<br>- បកស្រាយទំនាក់ទំនងរវាងតម្រុយចម្ងាយចរ បម្លាស់ទី វ៉ិចទ័រល្បឿន និងវ៉ិចទ័រសម្ទុះ<br>- បកស្រាយអំពីល្បឿនថេរ  សម្ទុះថេរតាមក្រាប<br>- កំណត់នូវវ៉ិចទ័រល្បឿនខណៈ និងក្រាបបម្លាស់ទីជាអនុគមន៍នៃពេល<br>- កំណត់នូវសម្ទុះមធ្យម សម្ទុះខណៈ និងក្រាបល្បឿនជាអនុគមន៍នៃពេល<br>- គណនាចម្ងាយចរតាមក្រាប<br>- គណនាសម្ទុះមធ្យម និងសម្ទុះខណៈ<br>- សរសេរសមីការស៊ីនេទិចនៃល្បឿនថេរ<br>- សរសេរសមីការស៊ីនេទិចនៃសម្ទុះថេរ | ១៥ម៉ |

| | | |
|---|---|---|
| | - គណនាមេគុណប្រាប់ទិសនៃក្រាបបម្លាស់ទីជាអនុគមន៍នៃពេល<br>- គណនាមេគុណប្រាប់ទិសនៃក្រាបល្បឿនជាអនុគមន៍នៃពេល<br>- ដោះស្រាយលំហាត់ដោយអនុវត្តរូបមន្តបានយ៉ាងត្រឹមត្រូវ<br>- ធ្វើពិសោធន៍៖ ទន្លាក់សេរី។<br>**ចរិយាសម្បទា**<br>- បណ្ដុះស្មារតីប្រុងប្រយត្នក្នុងកាបើកបរដោយពិនិត្យកុងទ័រល្បឿនជាខ្នាត km/h។ | |
| **មេរៀនទី៣ : ច្បាប់ញូតុន**<br>៣.១- ច្បាប់ទី១ញូតុន<br>និងប្រព័ន្ធគោលនិចលភាព<br>៣.២- ច្បាប់ទី២ញូតុន<br>៣.៣- ច្បាប់ទី៣ញូតុន<br>៣.៤- អនុវត្តច្បាប់ញូតុន | **វិជ្ជាសម្បទា**<br>- ប្រាប់ច្បាប់ញូតុននៃចលនា ទី១ ទី២ និងទី៣<br>- ប្រាប់ពីប្រព័ន្ធនិចលភាពបានត្រឹមត្រូវ។<br>**បំណិនសម្បទា**<br>- បង្ហាញពីច្បាប់ទី១ញូតុន<br>- បង្ហាញពីច្បាប់ទី២ញូតុន<br>- បង្ហាញពីច្បាប់ទី៣ញូតុន<br>- អនុវត្តច្បាប់ញូតុន ប្លង់ទេរ រ៉ក និងបន្ទប់យោង។<br>**ចរិយាសម្បទា**<br>- អភិវឌ្ឍចំណេះដឹងលើការអនុវត្តច្បាប់ញូតុនទាំងបីក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ | ១២ម៉ |
| **មេរៀនទី៤ : កម្មន្ត ថាមពល និងអានុភាព**<br>៤.១- កម្មន្តនៃកម្លាំងថេរ<br>៤.២- ថាមពលស៊ីនេទិច<br>៤.៣- ទ្រឹស្តី កម្មន្ត-ថាមពលស៊ីនេទិច<br>៤.៤- ច្បាប់រក្សាថាមពលមេកានិច<br>៤.៥- អានុភាព | **វិជ្ជាសម្បទា**<br>- ប្រាប់បានថាកម្មន្តជាទំហំស្កាលែនិងបញ្ជាក់អំពីកម្មន្តចលករ កម្មន្តទប់ និងការមិនធ្វើកម្មន្ត<br>- រៀបរាប់បានច្បាស់លាស់ពីផ្ទៃក្រឡាខណ្ឌដោយក្រាបនៃកម្លាំងនិងចម្ងាយចរគឺជាកម្មន្ត<br>- ប្រាប់ទ្រឹស្តី កម្មន្ត-ថាមពលស៊ីនេទិច<br>- ពោលច្បាប់រក្សាថាមពលមេកានិច<br>- ឱ្យនិយមន័យច្បាស់ពីអានុភាព។<br>**បំណិនសម្បទា**<br>- ធ្វើពិសោធន៍យកទិន្នន័យអំពីច្បាប់រក្សាថាមពលមេកានិច<br>- បង្ហាញពីទំនាក់ទំនងរវាង កម្មន្ត ថាមពលស៊ីនេទិច និងអានុភាព<br>- ដោះស្រាយបញ្ហាទាក់ទងនឹងថាមពល និងអានុភាពក្នុងជីវភាពប្រចាំថ្ងៃ។<br>**ចរិយាសម្បទា**<br>- អភិវឌ្ឍចំណេះដឹងក្នុងការប្រើប្រាស់ថាមពលមេកានិច | ១២ម៉ |

| | | |
|---|---|---|
| | តាមស្ថានភាពផ្សេងៗ<br>- បណ្ដុះស្មារតីសន្សំសំចៃថាមពលដោយច្នៃប្រឌិតឧបករណ៍ប្រើប្រាស់ជាដើម។ | |
| **មេរៀនទី៥ : សម្ពាធនៃសន្ទនីយ៍ស្ដាទិច**<br>៥.១- រំលឹកឡើងវិញពីដង់ស៊ីតេ<br>៥.២- សម្ពាធ<br>៥.២.១- អត្ថិភាពនៃសម្ពាធបរិយាកាស សម្ពាធអាស្រ័យនឹងជម្រៅរបស់សន្ទនីយ៍<br>៥.២.២- គោលការណ៍គ្រឹះអ៊ីដ្រូលិច<br>៥.៣- ការវាស់សម្ពាធឧស្ម័នម៉ាណូម៉ែត្របារ៉ូម៉ែត្របារត<br>៥.៤- អនុវត្តសម្ពាធ និងគោលការណ៍អាកស៊ីម៉ែត្រ<br>៥.៤.១- គោលការណ៍អាកស៊ីម៉ែត្រ និងកម្លាំងដំណោល<br>**ពិសោធន៍** | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីមូលហេតុ ដែលអង្គធាតុខ្លះលិច និងអណ្ដែតក្នុងអង្គធាតុរាវ<br>- ប្រាប់ភាពខុសគ្នារវាងសម្ពាធបរិយាកាស សម្ពាធឧស្ម័ន និងសម្ពាធអង្គធាតុរាវ<br>- រៀបរាប់ពីគោលការណ៍គ្រឹះអ៊ីដ្រូលិច។<br>**បំណិនសម្បទា**<br>- គណនាសម្ពាធឱ្យបានត្រឹមត្រូវ<br>- ញែកភាពខុសគ្នារវាងសម្ពាធបរិយាកាស សម្ពាធឧស្ម័ន និងសម្ពាធសម្ពាធអង្គធាតុរាវ<br>- បង្ហាញពីគោលការណ៍ប៉ាស្កាល់ និងគោលការណ៍អាកស៊ីម៉ែត្រ<br>- ធ្វើពិសោធន៍អនុវត្តអំពីច្បាប់រក្សាថាមពលមេកានិច។<br>**ចរិយាសម្បទា**<br>- ជំរុញឱ្យយកចិត្តទុកដាក់ក្នុងការសង្កេតកត់ត្រាពេលធ្វើពិសោធ<br>- បណ្ដុះស្មារតីប្រុងប្រយត្នក្នុងការប្រើប្រាស់ឧបករណ៍វាស់សម្ពាធនិងរក្សាទុកដាក់ឱ្យបានល្អ។ | ១៤ម៉ |
| **មេរៀន៦ : ជីវិត និងថាមពល**<br>៥. ១-ប្រភពថាមពល<br>៥. ២-ប្រភពថាមពលផលិតឡើងវិញ និងមិនអាចផលិតឡើងវិញ<br>៥.៣- ផលប៉ះពាល់លើបរិស្ថាន | **វិជ្ជាសម្បទា**<br>- រៀបរាប់ប្រភពថាមពលនិងដំណើរការផលិតថាមពល<br>- រៀបរាប់ពីផលប៉ះពាល់នៃថាមពល និងផលប៉ះពាល់ពីរោងចក្រផលិតថាមពល។<br>**បំណិនសម្បទា**<br>- ពន្យល់ពីដំណើរការនៃថាមពលផលិតឡើងវិញនិងមិនអាចផលិតឡើងវិញ<br>- បង្ការ និងការការពារបរិស្ថាន។<br>**ចរិយាសម្បទា**<br>- បណ្ដុះស្មារតីក្នុងការប្រើប្រាស់ថាមពលនិងបម្រុងប្រយត្ន ពីផលប៉ះពាល់លើបរិស្ថាន។ | ៣ម៉ |
| **ជំពូក២ : ទែម៉ូឌីណាមិច** | | **១៦ម៉** |
| **មេរៀនទី១ : សីតុណ្ហភាពនិងកម្ដៅ**<br>១.១- សីតុណ្ហភាព និងទែម៉ូម៉ែត្រ | **វិជ្ជាសម្បទា**<br>- ឱ្យនិយមន័យសីតុណ្ហភាព | ១៦ម៉ |

| | | |
|---|---|---|
| ១.២- មាត្រដ្ឋានសីតុណ្ហភាព និងបម្លាស់ប្តូរខ្នាត<br>១.៣- កម្តៅ និងច្បាប់ទីសូន្យ ទែម៉ូឌីណាមិច<br>១.៤- សមភាពគ្នារវាងកម្មន្ត និងកម្តៅ តាមការពិសោធន៍របស់លោកស៊ូល<br>១.៥- ចំណុះកម្តៅ កម្តៅម៉ាស និងការវាស់បរិមាណកម្តៅ<br>១.៦- កម្តៅឡាតង់ ចំណុចរលាយ ចំណុចរំពុះ និងចំណុចកកនៃអង្គធាតុ<br>**ពិសោធន៍** កាឡូរីម៉ែត្រ | - ប្រាប់ពីទំនាក់ទំនងមាត្រដ្ឋានសីតុណ្ហភាពរវាង សីតុណ្ហភាពសតភាគ និងសីតុណ្ហភាពកែលវិន (ឬសីតុណ្ហភាពដាច់ខាត)<br>- រៀបរាប់ទំនាក់ទំនងមាត្រដ្ឋានសីតុណ្ហភាព រវាង សីតុណ្ហភាពជាផារិនហៃ និងសីតុណ្ហភាពជាសែលស៊ុស (ឬសតភាគ)<br>- ឱ្យនិយមន័យកម្តៅឱ្យបានច្បាស់លាស់<br>- ឱ្យរូបមន្តថាមពលកម្តៅស្រូបឬបញ្ចេញរបស់អង្គធាតុ។<br>**បំណិនសម្បទា**<br>- ពន្យល់យ៉ាងច្បាស់លាស់អំពីចំណុះកម្តៅ<br>- ពន្យល់ពីភាពទាំងបីនៃរូបធាតុ និងទម្រង់របស់វាបានច្បាស់លាស់<br>- ពន្យល់ពីចលនារបស់ម៉ូលេគុលនៃភាពរបស់អង្គធាតុ<br>- ពន្យល់អត្ថន័យនៃលំនឹងថាមពលកម្តៅតាមច្បាប់ទីសូន្យ ទែម៉ូឌីណាមិចនិងការវាស់ដោយប្រើទែម៉ូម៉ែត្រ<br>- ពន្យល់យ៉ាងច្បាស់លាស់អំពីកម្តៅឡាតង់ (ការលាយ កំណក កំណរជាញើស បង្ហួត និងរំហួត និងចំហេះ បានត្រឹមត្រូវ)<br>- ធ្វើពិសោធន៍កាឡូរីម៉ែត្រដើម្បីរកកម្តៅម៉ាសរបស់អង្គធាតុ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីប្រុងប្រយត្ននៅពេលពិសោធ<br>- ស្រឡាញ់រក្សាទុកដាក់ឧបករណ៍ក្រោយពេលពិសោធ។ | |
| **ជំពូកទី៣ : អេឡិចត្រូស្តាទិច** | | **២៤ម៉** |
| **មេរៀនទី១ : បន្ទុក និងដែនអគ្គិសនី**<br>១.១- បន្ទុកអគ្គិសនី អង្គធាតុចម្លង និងអ៊ីសូឡង់<br>១.២- ការផ្ទុកបន្ទុក<br>១.៣- ច្បាប់គូឡំ<br>១.៤- ដែនអគ្គិសនី និងខ្សែដែនអគ្គិសនី<br>១.៥- ខ្សែដែនអគ្គិសនីឯកសណ្ឋាន<br>១.៦- ច្បាប់ហ្គូស<br>១.៧- ចលនាបន្ទុកក្នុងដែនអគ្គិសនីឯកសណ្ឋាន<br>១.៨- គ្រឿងចម្លងក្នុងលំនឹងអេឡិចត្រូស្តាទិច<br>១.៩- អនុវត្តន៍ខ្លះៗនៃអេឡិចត្រូស្តា ទិចៈ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីប្រភេទបន្ទុកអគ្គិសនី<br>- ពណ៌នាអំពីអគ្គិសនីកម្មដោយការត្រដុសទាក់ទងទៅនឹងការផ្ទេរអេឡិចត្រុង<br>- ប្រាប់ច្បាប់គូឡំ។<br>**បំណិនសម្បទា**<br>- ពន្យល់អត្ថន័យនៃដែនអគ្គិសនី<br>- ពន្យល់ពីអគ្គិសនីស្តាទិចនិងធ្វើពិសោធន៍បង្ហាញ<br>- បង្ហាញពីអគ្គិសនីកម្មក្នុងជីវភាពប្រចាំថ្ងៃ ដូចជាបុព្វហេតុដែលកើតមានរន្ទះ និងមានបន្ទុកអគ្គិសនីនៅក្នុងខ្លួនមនុស្ស<br>- បង្ហាញពីលក្ខណៈ ដែនអគ្គិសនី | ១២ម៉ |

| | | |
|---|---|---|
| ម៉ាស៊ីនកូពី និងព្រីនធើ<br>**ពិសោធន៍**<br>**បង្ហាញអន្តរកម្មបន្ទុកអគ្គិសនី** | នៅចន្លោះបន្ទះលោហៈពីរស្របគ្នាដែលផ្ទុកបន្ទុកអគ្គិសនីផ្ទុយគ្នា និងតម្លៃស្មើគ្នា<br>- ពិសោធបង្ហាញអន្តរកម្មបន្ទុកអគ្គិសនី។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីប្រុងប្រយត្ននៅពេលពិសោធ។ | |
| **មេរៀនទី២ : ប៉ូតង់ស្យែលអគ្គិសនី និងថាមពលប៉ូតង់ស្យែលអគ្គិសនី**<br>២.១- ផលសងប៉ូតង់ស្យែល និងថាមពលប៉ូតង់ស្យែលអគ្គិសនី<br>២.២- ប៉ូតង់ស្យែលអគ្គិសនី និងថាមពល<br>២.៣- ប៉ូតង់ស្យែលអគ្គិសនីធ្វើឡើងដោយចំនុចបន្ទុក<br>២.៤- ប៉ូតង់ស្យែល និងគ្រឿងចម្លងដែលផ្ទុកបន្ទុក<br>២.៥- អេឡិចត្រុងវ៉ុល<br>២.៦- ផ្ទៃអេគីប៉ូតង់ស្យែលអគ្គិសនី<br>២.៧-អនុវត្តន៍ | **វិជ្ជាសម្បទា**<br>- ពិពណ៌នាពីប៉ូតង់ស្យែលនិងថាមពលប៉ូតង់ស្យែលអគ្គិសនី<br>- ពិពណ៌នាពីទំនាក់ទំនងរវាងផលសងប៉ូតង់ស្យែលនិងថាមពលប៉ូតង់ស្យែលអគ្គិសនី។<br>**បំណិនសម្បទា**<br>- ពន្យល់នូវខ្សែអេគីប៉ូតង់ស្យែលនិងផ្ទៃអេគីប៉ូតង់ស្យែល<br>- អនុវត្តថាមពលផលសងប៉ូតង់ស្យែលអគ្គិសនីនៅចន្លោះបន្ទះលោហៈពីរស្របគ្នា ផ្ទុកបន្ទុកអគ្គិសនីផ្ទុយគ្នា និងតម្លៃស្មើគ្នា ដែលបង្កើតដែនអគ្គិសនីឯកសណ្ឋាន<br>- បង្ហាញបរិមាណបន្ទុកនៅលើបន្ទះលោហៈពីរសមាមាត្រនឹងផលសងប៉ូតង់ស្យែលរវាងបន្ទះស្របទាំង២<br>- បង្ហាញពីប៉ូតង់ស្យែលនៃចំនុចបន្ទុកអគ្គិសនី<br>- បង្ហាញនូវការប្រើផ្ទៃអេគីប៉ូតង់ស្យែលដែលប្រែប្រួលនៅជុំវិញចំណុចបន្ទុក<br>- ប្រៀបធៀបដែនអគ្គិសនីនិងខ្សែអេគីប៉ូតង់ស្យែល<br>- បកស្រាយនូវទំនាក់ទំនងរវាងអេឡិចត្រុងវ៉ុលនិងថាមពល។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីប្រុងប្រយត្នក្នុងពេលធ្វើពិសោធន៍។ | ១២ម៉ |
| **ជំពូក៤ : ម៉ាញេទិច** | | **១៤ម៉** |
| **មេរៀនទី១ : ដែនម៉ាញេទិចនៃចរន្តអគ្គិសនី**<br>១.១- មេដែក<br>១.២- ដែនម៉ាញេទិចនៃផែនដី<br>១.៣- ដែនម៉ាញេទិច<br>១.៤- កម្លាំងម៉ាញេទិចលើចរន្តត្រង់ (Current-carrying conductor)<br>អំណាន៖ ម៉ូម៉ង់កម្លាំងលើចរន្តវង់ និង ម៉ូទ័រអគ្គិសនី<br>១.៥- ចលនាបន្ទុកក្នុងដែនអគ្គិសនី<br>១.៦- ដែនម៉ាញេទិចនៃចរន្តត្រង់ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីដែនអេឡិចត្រូម៉ាញេទិច និងការអនុវត្តរបស់វា<br>- ឱ្យនិយមន័យដែនម៉ាញេទិច<br>- រៀបរាប់ពីវិធានកំណត់ដែនម៉ាញេទិចនៃចរន្តវង់។<br>**បំណិនសម្បទា**<br>- បង្ហាញពីដែនម៉ាញេទិចនៅចន្លោះបូប៊ីនហ៊ឹម-ហ៊ុល<br>- បកស្រាយពីលក្ខណៈដែនម៉ាញេទិចនៃសូលេណូអ៊ីតនិងការកំណត់ដែន<br>- គណនាដែនម៉ាញ៉េទិចជុំវិញចរន្តត្រង់<br>- បង្ហាញពីអន្តរកម្មនៃខ្សែចម្លងត្រង់ពីរនិងការបកស្រាយ | ១៤ម៉ |

| | | |
|---|---|---|
| និងច្បាប់អំពែ<br>១.៧- កម្លាំងមាញ៉េទិចរវាងខ្សែចម្លងត្រង់ពីរ<br>១.៨- ដែនម៉ាញេទិចនៃចរន្តវង់<br>១.៩- ដែនម៉ាញ៉េទិចនៃសូលីណូអ៊ីត | កម្លាំងអន្តរកម្មរវាងវាទាំងពីរ<br>- បង្ហាញពីការអនុវត្តម៉ូទ័រអគ្គិសនីដែលផ្ទុយពីគោលការណ៍ឌីណាម៉ូចរន្តឆ្លាស់។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីប្រុងប្រយត្នក្នុងប្រើប្រាស់ឧបករណ៍ដែលទាក់ទាងនឹងដែនម៉ាញេទិចក្នុងជីវភាពប្រចាំថ្ងៃ<br>- អភិវឌ្ឍចំណេះដឹងក្នុងប្រើប្រាស់ត្រីវិស័យ។ | |
| **ជំពូក៥ : អុបទិច** | | **២០ម៉** |
| **មេរៀនទី១ : ចំណាំងផ្លាតនិងចំណាំងបែរនៃពន្លឺ**<br>១.១- ធម្មជាតិនៃពន្លឺ<br>១.២- ការវាស់ល្បឿនពន្លឺវិធីរ៉ូម៉ែរ និង វិធីហ្វីហ្សូ<br>១.៣- ចំណាំងផ្លាតនិង ចំណាំងបែរ នៃពន្លឺ<br>១.៤- សន្ទស្សន៍ចំណាំងបែរ<br>១.៥- រប៉ាយពន្លឺ (Dispersion) និង ព្រីស<br>១.៦- ឥន្ទធនូ<br>១.៧- គោលការណ៍ហុយគែន<br>១.៨- ចំណាំងផ្លាតក្នុងទាំងស្រុង<br>១.៩- អំណាន: Fiber Optics<br>១.១០- គោលការណ៍ហ្វឺម៉ាត | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីការវាស់ល្បឿនពន្លឺតាមវិធីរ៉ូម៉ែរ និង វិធីហ្វីហ្សូ<br>- ពន្យល់ពីចំណាំងផ្លាត និងចំណាំងបែរនៃពន្លឺ<br>- ពណ៌នាបានពីដំណាលរបស់កាំពន្លឺឆ្លងកាត់មជ្ឈដ្ឋានផ្សេងៗដូចជាឡង់ទី...។<br>**បំណិនសម្បទា**<br>- បង្ហាញពីធម្មជាតិរបស់ពន្លឺ<br>- ពន្យល់បានត្រឹមត្រូវអំពីបាតុភូតឥន្ទធនូ<br>- អនុវត្តគោលការណ៍ហុយគែននិងហ្វឺម៉ាតក្នុងជីវភាពប្រចាំថ្ងៃ<br>- ដោះស្រាយលំហាត់ចំណាំងផ្លាតនិង ចំណាំងបែរ នៃពន្លឺដោយប្រើប្រាស់រូបមន្តបានត្រឹមត្រូវ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីប្រុងប្រយត្នក្នុងការប្រើប្រាស់ឧបករណ៍អុបទិចក្នុងជីវភាពប្រចាំថ្ងៃ។ | ១២ម៉ |
| **មេរៀនទី២ : ប្រព័ន្ធឡង់ទី**<br>២.១- ឡង់ទីស្តើង និងគំនូសសម្គាល់នៃកាំពន្លឺ<br>២.២- ឡង់ទី និង Aberrations | **វិជ្ជាសម្បទា**<br>- ឱ្យនិយមន័យឡង់ទី និងបង្ហាញភាពខុសគ្នា រវាងឡង់ទីបង្រួម និងឡង់ទីពង្រីក<br>- ពណ៌នាបានពីដំណាលរបស់កាំបន្លឺឆ្លងកាត់មជ្ឈដ្ឋានរូបផ្សេងៗដូចជាឡង់ទី...។<br>**បំណិនសម្បទា**<br>- កំណត់ចម្ងាយកំណុំឡង់ទីដូចជាភ្នែក ម៉ាស៊ីនថត កែវពង្រីក តេឡេស្កុបជាដើម<br>- យល់ពីឡង់ទីបង្រួម ពង្រីក កំណុំវត្ថុ កំណុំរូបភាព។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីប្រុងប្រយត្នក្នុងការប្រើប្រាស់ឧបករណ៍អុបទិចក្នុងជីវភាពប្រចាំថ្ងៃ។ | ៨ម៉ |

## ៧.២- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១១ (១សប្តាហ៍ ៤ម៉ោង ១ឆ្នាំសិក្សា ១៤០ម៉ោង)

វត្ថុបំណងកម្មវិធីលម្អិតថ្នាក់ទី១១ ផ្តល់ឱ្យសិស្សនូវផ្នែកៈ

### ១- វិជ្ជាសម្បទា

- **មេកានិចៈ** ចលនាក្នុងប្លង់ អនុវត្តច្បាប់ញូតុន កម្មន្ត ថាមពល អានុភាព ថាមពលប៉ូតង់ស្យែល និងការរក្សាថាមពល បរិមាណចលនា និងការទង្គិច មេកានិចសន្ទនីយ៍
- **ទែម៉ូឌីណាមិចៈ** ការរីកនៃអង្គធាតុ ការបញ្ជូនកម្តៅ និងឧស្ម័នបរិសុទ្ធ
- **រលកៈ** ចលនាខួប រលកសូរ និងសណ្តាប់ឮ
- **អគ្គិសនី និងម៉ាញេទិចៈ** កុងដង់សាទ័រ ចរន្ត ដនិតាអគ្គិសនី និងសៀគ្វីចរន្តជាប់។

### ២- បំណិនសម្បទា

ដោយផ្អែកលើចំណេះដឹងខាងលើ សិស្សអាចៈ

- ពន្យល់ បកស្រាយ បង្ហាញ និងអនុវត្តតាមផ្នែកនិងមេរៀននីមួយៗបានច្បាស់លាស់
- ធ្វើពិសោធតាមបែបបរិមាណ និងបែបគុណភាពនៃមេរៀននីមួយៗ និងចេះប្រើឧបករណ៍ពិសោធបានត្រឹមត្រូវតាមវិធីវិទ្យាសាស្ត្រ
- ពន្យល់បានច្បាស់លាស់នូវបាតុភូតរូបវិទ្យាទាំងក្នុងទ្រឹស្តី និងក្នុងជីវភាពរស់នៅ
- ឆ្លើយសំណួរបានរហ័ស និងត្រឹមត្រូវតាមទ្រឹស្តីវិទ្យាសាស្ត្រ
- គណនាលំហាត់រហ័សដោយប្រើរូបមន្តបានត្រឹមត្រូវ
- បង្ហាញឱ្យឃើញថា មុខវិជ្ជារូបវិទ្យាបម្រើឱ្យផលប្រយោជន៍ក្នុងជំនាញនានាទៅអនាគតតាមតម្រូវការទីផ្សារការងារ។

### ៣. ចរិយាសម្បទា

- ផ្លាស់ប្តូរទម្លាប់ឱ្យមានស្មារតីទទួលខុសត្រូវខ្ពស់នៅពេលជួបប្រទះរាល់បញ្ហាទាំងក្នុងការសិក្សា និងក្នុងជីវភាពរស់នៅប្រចាំថ្ងៃ
- បណ្តុះស្មារតីច្នៃប្រឌិតលើសកម្មភាពស្វែម និងផលិតសម្ភារៈឧបទេសងាយៗដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ
- អភិវឌ្ឍចំណេះដឹង និងមានចំណូលចិត្តក្នុងការស្រាវជ្រាវព័ត៌មានថ្មីៗដែលទាក់ទងនឹងវិទ្យាសាស្ត្រ។

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| **ជំពូក ១ : មេកានិច** | | **៦២ម៉** |
| **មេរៀនទី១ : ចលនាក្នុងប្លង់**<br>១.១- វ៉ិចទ័រទីតាំង និងបំលាស់ទី<br>១.២- ល្បឿន (វ៉ិចទ័រល្បឿន<br>វ៉ិចទ័រល្បឿនខណៈ<br>វ៉ិចទ័រល្បឿនមធ្យម)<br>១.៣- សម្ទុះ (វ៉ិចទ័រសម្ទុះមធ្យម និងសម្ទុះ | **វិជ្ជាសម្បទា**<br>- ឱ្យនិយមន័យវ៉ិចទ័រទីតាំងនិងរកឧទាហរណ៍បញ្ជាក់<br>- ឱ្យនិយមន័យល្បឿន និងសម្ទុះ<br>- ឱ្យនិយមន័យចលនាវង់ស្មើ។<br>**បំណិនសម្បទា**<br>- បង្ហាញនូវចលនាក្នុងប្លង់(ចលនាតាមពីរវិមាត្រ)ដោយអនុវត្ត | ១២ម៉ |

| | | |
|---|---|---|
| ខណៈ)<br>១.៤- ចលនាដោយសម្ទុះថេរ<br>១.៥- ចលនាគ្រាប់បាញ់<br>១.៦- ល្បឿនធៀប<br>១.៧- ចលនាវង់ស្មើ(ទីតាំងមុំ ល្បឿនមុំ វ៉ិចទ័រល្បឿនមុំ សម្ទុះមុំ និងវ៉ិចទ័រសម្ទុះមុំ)<br>១.៨- សមីការស៊ីនេម៉ាទិចនៃចលនារង្វិលដែលមានសម្ទុះមុំថេរ<br>**ពិសោធន៍ ៖ ចលនាគ្រាប់បាញ់** | ចលនាត្រង់ស្មើនិងចលនាត្រង់ប្រែប្រួលស្មើ<br>- បង្ហាញនូវសមីការចលនាគ្រាប់បាញ់ដែលគន្លងមានរាងជាប៉ារ៉ាបូលជាអនុគមន៍នឹងចម្ងាយធ្លាក់<br>- បង្ហាញនូវចម្ងាយធ្លាក់អតិបរមា<br>- បង្ហាញនូវសមីការកម្ពស់ឡើងដល់អតិបរមា<br>- បង្ហាញល្បឿនមុំអនុគមន៍នឹងល្បឿនប្រវែង<br>- បង្ហាញនូវទំនាក់ទំនង ទីតាំងមុំ ល្បឿនមុំ និងល្បឿនប្រវែង<br>- បកស្រាយសម្ទុះមុំនិងវ៉ិចទ័រសម្ទុះមុំ<br>- បកស្រាយសមីការស៊ីនេទិចចលនាវង់នៃសម្ទុះថេរ<br>- ពិសោធបង្ហាញ៖ ចលនាគ្រាប់បាញ់<br>- ពិសោធបង្ហាញចលនាគ្រាប់បាញ់។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីចលនាផ្សេងៗដែលកើតមានក្នុងប្លង់ ហើយចេះប្រៀបធៀបចលនាមួយទៅចលនាមួយទៀត<br>- អភិវឌ្ឍចំណេះដឹងពីការបាញ់បានចម្ងាយអតិបរមា និងកម្ពស់អតិបរមា។ | |
| **មេរៀនទី២ : អនុវត្តន៍ច្បាប់ញូតុន**<br>២.១- កម្លាំងកកិត<br>២.២- ចលនាវង់ស្មើ<br>២.៣- ការអនុវត្តផ្លូវកោងក្នុងជីវភាពរស់នៅ<br>២.៤- ចលនាវង់ប្រែប្រួល<br>២.៥- ចល័តក្រោមវត្តមានកម្លាំងទប់<br>២.៦- កម្លាំងគ្រឹះក្នុងធម្មជាតិ | **វិជ្ជាសម្បទា**<br>- ឱ្យនិយមន័យកម្លាំងកកិត និងរូបមន្តកកិតស៊ីនេទិច និងកកិតស្តាទិច<br>- ឱ្យនិយមន័យចលនាវង់ប្រែប្រួល។<br>**បំណិនសម្បទា**<br>- ពន្យល់នូវកម្លាំងចូលផ្ចិតនិងកម្លាំងចាកផ្ចិត ព្រមទាំងគូសតាងដ្យាក្រាម<br>- អនុវត្តកម្លាំងចូលផ្ចិតនិងកម្លាំងចាកផ្ចិតក្នុងជីវភាពរស់នៅ៖ ផ្លូវកោង ផ្លូវវង់ ស្ពានផត ស្ពានកោង<br>- បង្ហាញពីបម្រុងប្រយត្ននៃការបើកបរលើផ្លូវកោង ស្ពានកោង ផ្លូវប៉ោង និងផ្លូវផត។<br>- អនុវត្តចលនាវង់ស្មើក្នុងជីវភាពប្រចាំថ្ងៃ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីក្នុងការប្រើប្រាស់កម្លាំងដើម្បីទទួលបានផលតាមការចង់បាន និងវិធីសាស្ត្ររបស់វា។<br>- យល់ពីកម្លាំងដ៏ច្រើនកើតមានជុំវិញខ្លួន តែតាមពិតកម្លាំងតែ៤ប៉ុណ្ណោះដែលកើតមានក្នុងធម្មជាតិ<br>- យល់ពីប្រព័ន្ធឡានទំនើបៗបំពាក់ដោយ ABS។ | ១០ម៉ |

| | | |
|---|---|---|
| **មេរៀនទី៣ : កម្មន្ត ថាមពល និងអានុភាព**<br>៣.១- កម្មន្តដោយកម្លាំងប្រែប្រួល<br>៣.២- ថាមពលស៊ីនេទិច និងទ្រឹស្តីកម្មន្ត-ថាមពលស៊ីនេទិច<br>៣.៣-អានុភាព និងទិន្នផល | **វិជ្ជាសម្បទា**<br>- បង្ហាញពីផលគុណស្កាលែ និងកម្មន្ត<br>- ប្រាប់បានច្បាស់លាស់ពីទ្រឹស្តីថាមពលស៊ីនេទិច<br>- ប្រាប់ពីអត្ថន័យនៃពាក្យអានុភាព និងទិន្នផល។<br>**បំណិនសម្បទា**<br>- ពន្យល់ច្បាស់នូវបញ្ញត្តិកម្មន្ត ថាមពល និងអានុភាព<br>- ពន្យល់ពីកម្មន្តដែលកើតឡើងដោយកម្លាំងថេរ និងកម្លាំងប្រែប្រួល<br>- ញែកច្បាស់រវាងថាមពល កម្មន្ត និងអានុភាព<br>- ពន្យល់ច្បាស់ពីអានុភាព និងទិន្នផល។<br>**ចរិយាសម្បទា**<br>- បណ្តុះគំនិតពីការប្រើប្រាស់កម្លាំងដោយចេះបកស្រាយពីទិន្នផលរបស់វា (ឬហៅប្រសិទ្ធភាព)<br>- មានទំនុកចិត្តក្នុងការប្រើប្រាស់ទ្រឹស្តីរក្សាថាមពលដើម្បីដោះបញ្ហាក្នុងជីវភាពប្រចាំថ្ងៃ។ | ៨ម៉ |
| **មេរៀនទី៤ : ថាមពលប៉ូតង់ស្យែល និងការរក្សាថាមពល**<br>៤.១- កម្លាំងរក្សា និងមិនរក្សា<br>៤.២- ថាមពលប៉ូតង់ស្យែលទំនាញដី<br>៤.៣- ថាមពលប៉ូតង់ស្យែលយឺត<br>៤.៤- ថាមពលមេកានិច និងច្បាប់រក្សាថាមពល<br>៤.៥- កម្មន្តធ្វើឡើងដោយកម្លាំងមិនរក្សា | **វិជ្ជាសម្បទា**<br>- ប្រាប់ពីកម្លាំងរក្សានិងកម្លាំងមិនរក្សា<br>- ប្រាប់ពីថាមពលប៉ូតង់ស្យែលទំនាញដីដែលធ្វើឡើងដោយកម្លាំងថេរ<br>- ប្រាប់ពីថាមពលប៉ូតង់ស្យែលយឺតរបស់រ៉ឺស័រដែលធ្វើឡើងដោយកំលាំងប្រែប្រួល។<br>**បំណិនសម្បទា**<br>- បង្ហាញពីកម្មន្តដែលធ្វើឡើងដោយកម្លាំងកកិតដែលជាកម្លាំងមិនរក្សា<br>- បកស្រាយថាមពលមេកានិច និង ច្បាប់រក្សាថាមពល<br>- យល់ពីកម្លាំងរក្សា មិនរក្សា និងកម្មន្តរបស់វា។<br>**ចរិយាសម្បទា**<br>- អភិវឌ្ឍចំណេះដឹងពីច្បាប់រក្សាថាមពលក្នុងជីវភាពប្រចាំថ្ងៃ។ | ១០ម៉ |
| **មេរៀនទី៥ : បរិមាណចលនា និងការទង្គិច**<br>៥.១- បរិមាណចលនា<br>៥.២- ច្បាប់រក្សាបរិមាណចលនា<br>៥.៣- បរិមាណចលនានិងអាំពុលស្យុង<br>៥.៤- ច្បាប់រក្សាថាមពល និង ច្បាប់រក្សាបរិមាណចលនាក្នុងទង្គិច<br>៥.៥- ទង្គិចខ្ទាត និងទង្គិចស្ទក់ក្នុងមួយវិមាត្រ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីនិយមន័យបរិមាណចលនា<br>- រៀបរាប់បានក្បោះក្បាយពីប្រភេទទង្គិច<br>- ប្រាប់ពីច្បាប់រក្សាបរិមាណចលនានិងច្បាប់រក្សាថាមពលក្នុងចលនាមួយវិមាត្រនិងពីរវិមាត្រ។<br>**បំណិនសម្បទា**<br>- ពន្យល់ច្បាស់នូវបញ្ញត្តិបរិមាណចលនានិងបម្រែបម្រួលបរិមាណចលនា | ១២ម៉ |

| | | |
|---|---|---|
| ៥.៦- ការទង្គិចក្នុងពីរវិមាត្រ<br>៥.៧- ផ្ចិតម៉ាស ប្រព័ន្ធភាគល្អិត និង អនុវត្តន៍<br>៥.៨- កម្លាំងក្រៅ និងចលនាផ្ចិតម៉ាស<br>៥.៩- កម្លាំងក្នុង និងចលនាផ្ចិតម៉ាស<br>៥.១០- ប្រព័ន្ធនៃម៉ាសប្រែប្រួល និងរ៉ុក្កែត | - បកស្រាយគោលការណ៍ បរិមាណចលនា-អាំពុលស្យុង<br>- ញែកច្បាស់រវាងទង្គិចខ្ទាត និងទង្គិចស្អក់<br>- បង្ហាញការអនុវត្តទង្គិចមួយវិមាត្រនិងពីរវិមាត្រក្នុងជីវភាពរស់នៅ<br>- អនុវត្តលើការជ្រើសរើសយកតម្រុយក្នុងការដោះស្រាយបញ្ហាក្នុងជីវភាពរស់នៅប្រចាំថ្ងៃដែលទាក់ទងនឹងកម្លាំង។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីស្រាវជ្រាវពីប្រព័ន្ធរ៉ុក្កែតដែលជាវិទ្យាសាស្រ្តចុងក្រោយនៅសតវត្សទី២១<br>- អភិវឌ្ឍចំណេះដឹងលើការទង្គិចដែលជួបប្រទះក្នុងជីវភាពប្រចាំថ្ងៃ។ | |
| **មេរៀនទី៦ : មេកានិចសន្ទនីយ៍**<br>៦.១ សម្ពាធក្នុងសន្ទនីយ៍និងបរិយាកាស(ច្បាប់ប៉ាស្កាល់)<br>៦.២ លំហូរសន្ទនីយ៍និងនិរន្តរភាព<br>៦.៣- សមីការប៊ែរនូយី (Bernoulli's Equation)<br>៦.៤- អនុវត្តសមីការប៊ែរនូយី<br>៦.៥- ភាពស្អិត(Viscosity) និងសមីការ Poiseuille<br>ពិសោធន៍៖ ពិសោធន៍បង្ហាញ (១)លំហូរនៃសន្ទនីយ៍(២)តំណឹងផ្ទៃ | **វិជ្ជាសម្បទា**<br>- ពណ៌នាពីភាពស្អិត និងតំណឹងផ្ទៃនៃសន្ទនីយ៍<br>- បង្ហាញសម្ពាធរបស់សន្ទនីយប្រែប្រួលទៅតាមល្បឿននិងកម្ពស់។<br>**បំណិនសម្បទា**<br>- បកស្រាយសមីការប៊ែណូយី<br>- ពន្យល់ពីល្បឿនសន្ទនីយច្រាសសមាមាត្រទៅនឹងផ្ទៃមុខកាត់បំពង់ស៊ីឡាំង<br>- អនុវត្តសមីការប៊ែណូយីក្នុងជីវភាពរស់នៅ<br>- ពិសោធបង្ហាញអំពីលំហូរនៃសន្ទនីយ៍និងតំណឹងផ្ទៃ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីប្រុងប្រយត្នក្នុងការជ្រើសរើសនិងប្រើប្រាស់បំពង់ជ័របូមទឹកនិងបាញ់ទឹកក្នុងជីវភាពរស់នៅ<br>- បណ្តុះស្មារតីប្រុងប្រយត្នពីផលប៉ះពាល់ត្រចៀកពេលជ្រមុជក្នុងទឹកពីជម្រៅ១០ម៉ែត្រទៅ<br>- អភិវឌ្ឍចំណេះដឹងលើការអនុវត្តលំហូរនៃសន្ទនីយក្នុងជីវភាពរស់នៅ។ | ១០ម៉ |
| **ជំពូក ២ : ទែម៉ូឌីណាមិច** | | **២០ម៉** |
| **មេរៀនទី១ : ការរីកនៃអង្គធាតុ និងការបញ្ជូនកម្តៅ**<br>១.១- ការរីកបណ្តោយនៃអង្គធាតុរឹង<br>១.២- ការរីកផ្ទៃនៃអង្គធាតុរឹង<br>១.៣- ការរីកមាឌនៃអង្គធាតុរឹង និងរាវ<br>១.៤- ការចម្លងកម្តៅ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីការរីកបណ្តោយនៃអង្គធាតុរឹង<br>- ប្រាប់ពីការរីកផ្ទៃនៃអង្គធាតុរឹង<br>- ប្រាប់ពីការរីកមាឌនៃអង្គធាតុរឹង និងរាវ<br>- ប្រាប់ពីវិធីនៃការបញ្ជូនកម្តៅ។ | ១០ម៉ |

| | | |
|---|---|---|
| ១.៥- ចរន្តវិលវល់<br>១.៦- ការបញ្ចេញរស្មី<br>**ពិសោធន៍:**ការរីកមាឌនៃឧស្ម័ន | **បំណិនសម្បទា**<br>- បង្ហាញការរីកនៃឧស្ម័នតាមរយៈកម្តៅ<br>- បកស្រាយការរីកបណ្តោយ រីកផ្ទៃ និងរីកមាឌនៃអង្គធាតុរឹង ។<br>- បកស្រាយការរីកមាឌនៃអង្គធាតុរាវ និងឧស្ម័ន<br>- បកស្រាយពីមេគុណរីកផ្ទៃ និងមេគុណរីកមាឌនៃអង្គធាតុរឹង<br>- បង្ហាញពីបរិមាណកំហូចទ្រង់ទ្រាយ ស្រ្តេស (Stress) និង ស្រ្តេន (Strain)។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីប្រុងប្រយត្នទៃការរីកបណ្តោយរបស់អង្គធាតុរឹង នៅក្នុងវិស័យសំណង់<br>- អភិវឌ្ឍចំណេះដឹងពីការបញ្ជូនកម្តៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ | |
| **មេរៀនទី២ : ឧស្ម័នបរិសុទ្ធ**<br>២.១- ម៉ាសម៉ូលេគុល ម៉ាសម៉ូល និងអាវ៉ូកាដ្រូ<br>២.២- សមីការភាពនៃឧស្ម័នបរិសុទ្ធ<br>-ច្បាប់ប៊យ-ម៉ារ៉ុត<br>-ច្បាប់សាល<br>-ច្បាប់កេលុយសាក់<br>-សមីការឧស្ម័នបរិសុទ្ធ<br>២.៣- គម្រូម៉ូលេគុលនៃរូបធាតុ<br>**ពិសោធន៍: ចលនាប្រោន** | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីលក្ខណៈនៃឧស្ម័នបរិសុទ្ធ<br>- ពិពណ៌នាអំពីរង្វាស់នៃសម្ពាធរបស់ឧស្ម័នដោយប្រើបារ៉ូម៉ែត្រ និងម៉ាណូម៉ែត្រ<br>- ពណ៌នានូវទំនាក់ទំនងរវាងសម្ពាធនិងមាឌឧស្ម័ននៅសីតុណ្ហភាពនិងចំនួនម៉ូលថេរ(ច្បាប់ប៊យ)និងសង់ក្រាប<br>- ពណ៌នានូវទំនាក់ទំនងរវាងមាឌនិងសីតុណ្ហភាពឧស្ម័ននៅខណៈសម្ពាធនិងចំនួនម៉ូលថេរ(ច្បាប់សាល)និងសង់ក្រាប<br>- ពណ៌នានូវទំនាក់ទំនងរវាងសម្ពាធនិងសីតុណ្ហភាព ឧស្ម័ននៅខណៈមាឌនិងចំនួនម៉ូលថេរ(ច្បាប់កេលុយសាក់) និងសង់ក្រាប<br>- ពណ៌នានូវទំនាក់ទំនងរវាងសម្ពាធ មាឌ ចំនួនម៉ូលេគុល និងសីតុណ្ហភាពឧស្ម័ន។<br>**បំណិនសម្បទា**<br>- អនុវត្តចំនួនអាវ៉ូកាដ្រូ<br>$N_A = 6.02\times10^{23}$ ម៉ូលេគុល $/mo\ell$<br>ថេរបុ៊លស្មាន់ $k_B = 1.38\times10^{-23} J/K$<br>និងថេរសកលនៃឧស្ម័ន $R = 8.31 J/mo\ell.K$<br>ក្នុងការដោះស្រាយលំហាត់<br>- បង្ហាញគម្រូម៉ូលេគុលនៃរូបធាតុនិងពិសោធចលនាប្រោន។<br>**ចរិយាសម្បទា**<br>- រក្សាសុវត្ថិភាពក្នុងការបញ្ចូល និងប្រើប្រាស់ Gas ក្នុងជីវភាពរស់នៅបានត្រឹមត្រូវ<br>- បណ្តុះប្រុងប្រយត្នក្នុងពេលបញ្ចូលខ្យល់ក្នុងកង់យានយន្ត។ | ១០ម៉ |

| ជំពូក ៣ : រលក | | ២៦ម៉ |
| --- | --- | --- |
| **មេរៀនទី១ : ចលនាខួប**<br>១.១- ខួបនិងចលនាលំយោល<br>១.២- ចលនាអាម៉ូនិចងាយ<br>១.៣- ទំនាក់ទំនងរវាងលំយោលអាម៉ូនិច និងចលនាវង់ស្មើ<br>១.៤- ប៉ោលទោល និងប៉ោលសមាស<br>១.៥- ថាមពលមេកានិចនៃប៉ោលទោល និងប៉ោលសមាស<br>១.៦- ប៉ោលរ៉ឺស័រលើអក្សដេក និងអក្សឈរ<br>១.៧- សមីការលំយោលអាកម៉ូនិចងាយ<br>១.៨- ថាមពលក្នុងចលនាលំយោលអាកម៉ូនិច<br>១.៩- លំយោលថយនិងលំយោលបង្ខំ<br>១.១០- រ៉េសូណង់<br>**ពិសោធន៍ ប៉ោលរ៉ឺស័រ** | **វិជ្ជាសម្បទា**<br>- រៀបរាប់អំពីលក្ខខណ្ឌនៃលំយោលអាកម៉ូនិចធម្មតា និងលើកយកស្ថានភាពនៃលំយោលដែលកើតមានក្នុងជីវភាពរស់នៅមកបញ្ជាក់<br>- ប្រាប់ពីទំនាក់ទំនងរវាងច្បាប់ហ៊ុកនិងច្បាប់ញូតុន (លំយោលករ ល្បឿន និងសម្ទុះក្នុងចលនាចលនាអាកម៉ូនិច)<br>- ប្រាប់ចលនាលំយោលស៊ីនុយសូអ៊ីតជាអនុគមន៍នឹង អំព្លីទុត ខួប ប្រេកង់ និងល្បឿនមុំ (ប្រេកង់មុំ)<br>- ប្រាប់បញ្ញត្តិថាមពលដើម្បីវិភាគលំយោលអាកម៉ូនិច<br>- ប្រាប់ពីប្រភេទលំយោលអាកម៉ូនិច<br>- ឱ្យនិយមន័យរបស់លំយោលថយ និងលំយោលបង្ខំ<br>- រៀបរាប់ពីបាតុភូតរេសូណង់ក្នុងលំយោលអាកម៉ូនិច។<br>**បំណិនសម្បទា**<br>- បង្ហាញនូវច្បាប់ហ៊ុកនិងទំនាក់ទំនងរបស់វាជាមួយច្បាប់ទី២ញូតុន<br>- ប្រៀបធៀបសមីការលំយោលអាកម៉ូនិចទៅនឹងចលនាវង់ស្មើដោយប្រើក្រាប<br>- បកស្រាយសមីការល្បឿន និងសមីការសម្ទុះ<br>- អនុវត្តគោលការណ៍លំយោលនៃប៉ោលទោល និងប៉ោលសមាស<br>- ពិសោធន៍លំយោលអាកម៉ូនិចដោយវាស់ខួបនៃលំយោលនិងច្បាប់រក្សាថាមពល។<br>**ចរិយាសម្បទា**<br>- អភិវឌ្ឍចំណេះដឹងលើបាតុភូតលំយោលផ្សេងៗក្នុងជីវភាពរស់នៅ។ | ១៤ម៉ |
| **មេរៀនទី២ : រលកសូរ និងសណ្តាប់ឮ**<br>២.១- ផាស និងចលនារលក<br>២.២- សមីការរលក<br>២.៣- ឌីណាមិចនៃចលនារលក (ល្បឿន និងមជ្ឈដ្ឋានរូប).<br>២.៤- ថាមពល អានុភាព និងអាំងតង់ស៊ីតេនៃរលកសូរ<br>២.៥- ចំណាំងផ្លាត និងអាំប៉េដង់ (Reflection and Impedance) | **វិជ្ជាសម្បទា**<br>- ឱ្យនិយមន័យរលកសូរ<br>- ពិពណ៌នានូវរលកសូរជាអនុគមន៍នៃបម្លាស់ទីភាគល្អិតឬបម្រែបម្រួលសម្ពាធ<br>- រៀបរាប់ពីបាតុភូតអាំងទែផេរ៉ង់ និងឌីប្រាក់ស្យុងសូរ។<br>**បំណិនសម្បទា**<br>- បង្ហាញពីដំហានរលកនៃសូរថយចុះខណៈចលនារបស់អង្គធាតុផ្លាស់ទី<br>- គណនាល្បឿននៃរលកសូរក្នុងមជ្ឈដ្ឋានដំណាលខុសគ្នា | ១២ម៉ |

| | | |
|---|---|---|
| ២.៦- កម្ពស់នៃសូរ (Pitch) ប្រេកង់សូរស្មុគស្មាញ (Complex sound)និង តែមសូរ<br>២.៧- ល្បឿន និងខួបនៃរលកសូរ<br>២.៨- រ៉េសូណង់ និងប្រអប់រេសូណង់សូរ<br>២.៩-អាំងទែផេរ៉ង់និងឌីប្រាក់ស្យុងនៃរលកសូរ<br>២.១០- ផលដូប្លេរ (Doppler effect)<br>២.១១- បាច់សូរ (Shock waves) | - គណនាដង់ស៊ីតេនៃរលកសូរ<br>- កំណត់នូវប្រេកង់សម្លេងបង្កើតដោយឧបករណ៍តន្ត្រីមួយចំនួន<br>- កំណត់នូវរ៉េសូណង់កើតឡើងក្នុងឧបករណ៍ភ្លេង<br>- គណនាប្រេកង់របស់អ្នកសង្កេត ខណៈប្រភពនៅស្ងៀម អ្នកសង្កេតផ្លាស់ទី ប្រភពផ្លាស់ទី អ្នកសង្កេតនៅស្ងៀម...។<br>**ចរិយាសម្បទា**<br>- មានបម្រុងប្រយ័ត្នក្នុងការប្រើប្រាស់ឧបករណ៍បំពងសម្លេងផ្សេងៗ<br>- អភិវឌ្ឍបច្ចេកទេសក្នុងការប្រើប្រាស់ឧបករណ៍តន្ត្រីមួយចំនួន<br>- ច្នៃប្រឌិតឧបករណ៍បង្កើតសូរ និងបញ្ជូនសូរ<br>- បណ្ដុះស្មារតីប្រុងប្រយ័ត្នពីបាតុភូតរេសូណង់និងបាច់សូរដែលកើតមានក្នុងជីវភាពប្រចាំថ្ងៃ។ | |
| **ជំពូក៤ : អគ្គិសនី** | | **៣២ម៉** |
| **មេរៀនទី១ : កុងដង់សាទ័រ**<br>១.១- កុងដង់សាទ័រ និងកាប៉ាស៊ីតេ<br>១.២- បន្ទះអាម៉ារតួនៃកុងដង់សាទ័រ<br>១.៣- បង្គុំកុងដង់សាទ័រ<br>១.៤- ថាមពលកុងដង់សាទ័រ<br>១.៥- កុងដង់សាទ័រជាមួយឌីអេឡិចទ្រិច<br>១.៦- ម៉ាស៊ីនបង្កើតបន្ទុកអគ្គិសនី(Vann de Graaff Machine)<br>ពិសោធន៍ កុងដង់សាទ័រតជាស៊េរី និងជាខ្នែង | **ចរិយាសម្បទា**<br>- ឱ្យនិយមន័យកុងដង់សាទ័រនិងកាប៉ាស៊ីតេ<br>- ឱ្យនិយមន័យឌីអេឡិចទ្រិចនៃកុងដង់សាទ័រ<br>- ប្រាប់ពីរបៀបនៃបង្គុំរបស់កុងដង់សាទ័រ។<br>**បំណិនសម្បទា**<br>- បកស្រាយរូបមន្តកាប៉ាស៊ីតេនៃកុងដង់សាទ័រប្លង់<br>- គណនាតង់ស្យុងនៅក្នុងឌីអេឡិចទ្រិច<br>- បកស្រាយពីដ្យាក្រាមនៃសៀគ្វីកុងដង់សាទ័រតជាស៊េរីនិងខ្នែង<br>- គណនា កាប៉ាស៊ីតេសមមូល តង់ស្យុងសមមូល បន្ទុកសមមូល តង់ស្យុងនិងបរិមាណបន្ទុកនៃកុងដង់សាទ័រនីមួយៗ<br>- បកស្រាយនូវគោលការណ៍និងដំណើរការរបស់ Vann de Graaff<br>- អនុវត្តកុងដង់សាទ័រក្នុងវេជ្ជសាស្ត្រ។<br>**ចរិយាសម្បទា**<br>- អភិវឌ្ឍចំណេះដឹងក្នុងការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិចផ្សេងៗក្នុងវេជ្ជសាស្ត្រ<br>- ស្រលាញ់ និង ស្វែងយល់បន្ថែមពីគ្រឿងអេឡិចត្រូនិចផ្សេងទៀត។ | ១០ម៉ |
| **មេរៀនទី២ : ចរន្ត និង រេស៊ីស្តង់**<br>២.១- ចរន្តអគ្គិសនី<br>២.២- ល្បឿនរំកិលនៃអេឡិចត្រុង | **វិជ្ជាសម្បទា**<br>- សរសេរច្បាប់អូម<br>- ប្រាប់រូបមន្តនិងខ្នាតរបស់ច្បាប់អូម | ១០ម៉ |

| | | |
|---|---|---|
| ២.៣- ឧបករណ៍វាស់ចរន្ត និងតង់ស្យុងក្នុង<br>សៀគ្វី<br>២.៤- រេស៊ីស្តង់ រេស៊ីស្ទីវីតេ និង<br>ច្បាប់អូម<br>២.៥- បម្រែបម្រួលនៃរេស៊ីស្តង់តាម<br>សីតុណ្ហភាព<br>២.៦- ស៊ុបព័រកុងឌុចទ័រ<br>២.៧- ថាមពល និងអានុភាពអគ្គិសនី<br>អំណាន៖ សកម្មភាពអគ្គិសនីនៅក្នុង<br>បេះដូង | - ពណ៌នាចលនារបស់អេឡិចត្រុងនិងរេស៊ីស្ទីវីតេនៃអង្គធាតុចម្លង<br>- រៀបរាប់ពីរេស៊ីស្ទីវីតេនៃអង្គធាតុផ្សេងៗ។<br>**បំណិនសម្បទា**<br>- កំណត់ទំនាក់ទំនងរវាងរេស៊ីស្ទីវីតេនិងសីតុណ្ហភាព<br>- កំណត់ទំនាក់ទំនងរវាងរេស៊ីស្តង់ និងសីតុណ្ហភាព<br>- គណនារេស៊ីស្តង់នៃខ្សែចម្លងបានត្រឹមត្រូវ<br>- គណនាថាមពលនិងអានុភាពអគ្គិសនីរបស់គ្រឿងទទួលបានត្រឹមត្រូវ។<br>**ចរិយាសម្បទា**<br>- បណ្ដុះស្មារតីប្រុងប្រយត្នក្នុងការប្រើប្រាស់ឧបករណ៍អគ្គិសនី<br>- អភិវឌ្ឍចំណេះដឹងក្នុងការជ្រើសរើសខ្សែចម្លងបានត្រឹមត្រូវដើម្បីកុំឱ្យខាតថាមពលអគ្គិសនីច្រើន។ | |
| **មេរៀនទី៣ : សៀគ្វីចរន្តជាប់**<br>៣.១- ប្រភពនៃកម្លាំងអគ្គិសនីចលករ<br>៣.២- បង្គុំរេស៊ីស្តរជាស៊េរី<br>៣.៣- បង្គុំរេស៊ីស្តរជាខ្នែង<br>៣.៣- ច្បាប់គៀរឆូហ្វ(Kirchhoff's Rules)<br>និងបង្គុំចម្រុះ<br>៣.៤- សៀគ្វី RC<br>អំណាន៖ ហ្គាវ៉ាណូម៉ែត អំពែម៉ែត្រ<br>និងវ៉ុលម៉ែត្រ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីប្រភពចរន្តជាប់<br>- ឱ្យនិយមន័យកម្លាំងអគ្គិសនីចលករ<br>- រៀបរាប់ពីរបៀបផ្គុំរេស៊ីស្តរ<br>- ប្រាប់ច្បាប់គៀរឆូហ្វ។<br>**បំណិនសម្បទា**<br>- ធ្វើគំនូសបំព្រួញនៃបង្គុំរេស៊ីស្តរក្នុងសៀគ្វី<br>- គណនារេស៊ីស្តង់ក្នុងបង្គុំជាស៊េរី និងខ្នែង<br>- បង្ហាញពីរបៀបបង្គុំចម្រុះ និងប្រើច្បាប់គៀរឆូហ្វដោះស្រាយលំហាត់បានត្រឹមត្រូវ<br>- ពន្យល់បានពីការប្រែប្រួលនៃចរន្តអគ្គិសនី និងបន្ទុកនៃកុងដង់សាទ័រក្នុងសៀគ្វីRC នៃចរន្តជាប់ ។<br>**ចរិយាសម្បទា**<br>- មានស្មារតីប្រុងប្រយត្នក្នុងការតភ្ជាប់គ្រឿងអគ្គិសនីប្រើប្រាស់ក្នុងគេហដ្ឋាន។ | ១២ម៉ |

## ៧.៣- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១២ (១សប្តាហ៍ ៤ម៉ោង ១ឆ្នាំសិក្សា ១៤០ម៉ោង)

វត្ថុបំណងកម្មវិធីលម្អិតថ្នាក់ទី១២ ផ្តល់ចំណេះដឹងបន្តពីថ្នាក់ទី១០ និងទី១១ ដូចជា៖

### ១- វិជ្ជាសម្បទា

- **ផ្នែកមេកានិច៖** ចលនារង្វិល ទំនាញសកល លំនឹងស្តាទិច និងភាពយឺត
- **ផ្នែកទែម៉ូឌីណាមិច៖** ទ្រឹស្តីស៊ីនេទិចនៃឧស្ម័ន ច្បាប់ទី១ ច្បាប់ទី២ ទែម៉ូឌីណាមិច និងម៉ាស៊ីនកម្តៅ
- **ផ្នែករលក៖** រលកមេកានិច និងរលកពន្លឺ
- **ផ្នែកម៉ាញេទិច៖** អាំងឌុចស្យុងអេឡិចត្រូម៉ាញេទិច អូតូអាំងឌុចស្យុង សៀគ្វីចរន្តឆ្លាស់ និងរលកអេឡិចត្រូម៉ាញេទិច
- **ផ្នែករូបវិទ្យាទំនើប៖** រូបវិទ្យាអង្គធាតុរឹង អេឡិចត្រូនិច ទម្រង់អាតូម រូបវិទ្យានុយក្លេអ៊ែ និងទ្រឹស្តីកង់ទិច។

### ២- បំណិនសម្បទា

ដោយផ្អែកលើចំណេះដឹងខាងលើ សិស្សអាច៖

- ពន្យល់ បកស្រាយ បង្ហាញ និងអនុវត្តតាមផ្នែកនិងមេរៀននីមួយៗបានច្បាស់លាស់
- ធ្វើពិសោធតាមបែបបរិមាណ និងបែបគុណភាពនៃមេរៀននីមួយៗ និងចេះប្រើឧបករណ៍ពិសោធបានត្រឹមត្រូវតាមវិធីវិទ្យាសាស្ត្រ
- ពន្យល់បានច្បាស់លាស់នូវបាតុភូតរូបវិទ្យាទាំងក្នុងទ្រឹស្តី និងក្នុងជីវភាពរស់នៅ
- ឆ្លើយសំណួរបានរហ័ស និងត្រឹមត្រូវតាមទ្រឹស្តីវិទ្យាសាស្ត្រ
- គណនាលំហាត់រហ័សដោយប្រើរូបមន្តបានត្រឹមត្រូវ
- បង្ហាញឱ្យឃើញថា មុខវិជ្ជារូបវិទ្យាបម្រើឱ្យផលប្រយោជន៍ក្នុងជំនាញនានាទៅអនាគតតាមតម្រូវការទីផ្សារការងារ។

### ៣- ចរិយាសម្បទា

- ផ្លាស់ប្តូរទម្លាប់ឱ្យមានស្មារតីទទួលខុសត្រូវខ្ពស់នៅពេលជួបប្រទះរាល់បញ្ហាទាំងក្នុងការសិក្សា និងក្នុងជីវភាព
  រស់នៅប្រចាំថ្ងៃ
- បណ្តុះស្មារតីច្នៃប្រឌិតលើសកម្មភាពស្វែង និងផលិតសម្ភារៈឧបទេសងាយៗដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ
- អភិវឌ្ឍចំណេះដឹងនិងមានចំណូលចិត្តក្នុងការស្រាវជ្រាវព័ត៌មានថ្មីៗដែលទាក់ទងនឹងវិទ្យាសាស្ត្រ
- បណ្តុះស្មារតីឱ្យមានការទទួលខុសត្រូវខ្ពស់ក្នុងការសម្រេចចិត្តជ្រើសរើសមហាវិទ្យាល័យដែលពួកគេត្រូវជ្រើសរើសនៅពេលបញ្ចប់មធ្យមសិក្សាទុតិយភូមិ។

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
| --- | --- | --- |
| **ជំពូក១ : មេកានិច** | | **២៨ម៉** |
| **មេរៀនទី១ : ចលនារង្វិល**<br>១.១- ទីតាំងមុំ ល្បឿនមុំ និងសម្ទុះមុំ<br>១.២- សមីការស៊ីនេម៉ាទិចនៃចលនារង្វិល ដែលមានសម្ទុះថេរ<br>១.៣- ថាមពលស៊ីនេទិចនៃចលនារង្វិល<br>១.៤- ទ្រឹស្តីបទអក្សស្រប<br>១.៥- ម៉ូម៉ង់កម្លាំង<br>១.៦- ច្បាប់ទី២ញូតុននៃចលនារង្វិល<br>១.៧- កម្មន្ត និងអានុភាពនៃចលនារង្វិល<br>១.៨- ម៉ូម៉ង់ស៊ីនេទិច ឬបរិមាណចលនា<br>១.៩- អាំពុលស្យុង<br>១.១០- ច្បាប់រក្សាបរិមាណចលនា | **វិជ្ជាសម្បទា**<br>- កំណត់អត្ថន័យនៃពាក្យទីតាំងមុំ វ៉ិចទ័រល្បឿនមុំ និងសម្ទុះមុំ<br>- ឱ្យនិយមន័យម៉ូម៉ង់នៃកម្លាំងរង្វិល<br>- ឱ្យទំនាក់ទំនងរវាងកម្លាំងនិងសម្ទុះមុំ<br>- ប្រាប់ពីទ្រឹស្តីបទអក្សស្រប<br>- ប្រាប់ពីកម្លាំងនិងម៉ូម៉ង់នៃកម្លាំង។<br>**បំណិនសម្បទា**<br>- បង្ហាញពីកម្មន្តនិងអានុភាពក្នុងចលនារង្វិល<br>- បង្ហាញពីការអនុវត្តចលនារង្វិលក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។<br>- គណនាកម្មន្តនិងអានុភាពក្នុងចលនារង្វិល<br>- បកស្រាយម៉ូម៉ង់និចលភាព ម៉ូម៉ង់ស៊ីនេទិចនៃចលនារង្វិល និងរមៀល<br>- អនុវត្តច្បាប់រក្សាថាមពលស៊ីនេទិចក្នុងចលនារង្វិលនិង ចលនារមៀល (កន្ត្រករិល រថភ្លើងក្មេងលេង)។<br>**ចរិយាសម្បទា**<br>- អភិវឌ្ឍចំណេះដឹងផ្នែកចលនារង្វិលក្នុងជីវភាពរស់នៅ ប្រចាំថ្ងៃ<br>- មានស្មារតីប្រុងប្រយត្នពីចលនារង្វិលដែលកើតមានក្នុង ជីវភាពប្រចាំថ្ងៃ រហូតដល់ដំណើរការរបស់ចក្កវាឡ។ | ១០ម៉ |
| **មេរៀនទី២ : ទំនាញសកល**<br>២.១- សង្ខេបព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ<br>២.២- ច្បាប់ញូតុនចំពោះទំនាញសកល<br>២.៣- តម្លៃសម្ទុះទំនាញដី $g$ និងថេរទំនាញសកល $G$<br>២.៤- សម្ទុះទម្លាក់សេរី និងកម្លាំងទំនាញ សកល<br>២.៥- ថាមពលប៉ូតង់ស្យែលទំនាញដី និង ល្បឿនចាកចេញ<br>២.៦- ចលនារបស់រណប<br>២.៧-ការយល់បន្ថែមទៀតលើអត្ថន័យ នៃច្បាប់ចម្រាស់ការ<br>២.៨- ភាពគ្មានទំងន់<br>២.៩- គន្លងអេលីព និង គន្លងបើក<br>២.១០- ច្បាប់កេព្លែនិងចលនារបស់ភព | **វិជ្ជាសម្បទា**<br>- បង្ហាញពីដំណើរការវិវត្តនៃការបកស្រាយរបស់អ្នកប្រាជ្ញ ទាក់ទងនឹងបាតុភូតទំនាញសកល<br>- ឱ្យច្បាប់ទំនាញសកលនិងគណនាកម្លាំងទំនាញរវាង អង្គធាតុពីរដែលមានអំពើលើគ្នាទៅវិញទៅមក<br>- ប្រាប់ពីទំនាក់ទំនងរវាងទម្ងន់អង្គធាតុដែលរងនូវកម្លាំង ទំនាញដី<br>- ប្រាប់ពីចលនារបស់រណប និងភព<br>- យល់ពីល្បឿនចាកចេញផុតទំនាញផែនដីរបស់យានអវកាស ដែលត្រូវគេបាញ់ទៅភពផ្សេងៗ<br>- យល់ពីភាពជោរ និងភាពនាចរបស់ទឹកសមុទ្រ<br>- យល់ពីការស្រាវជ្រាវថ្មីៗទាក់ទងរណ្ដៅខ្មៅ និងសារធាតុ ងងឹត។<br>**បំណិនសម្បទា**<br>- បកស្រាយនិងប្រើកន្សោមថាមពលប៉ូតង់ស្យែលទំនាញ | ១០ម៉ |

| | | |
|---|---|---|
| ២.១១- ការពិនិត្យមើលបន្ថែមទៀត លើលក្ខណៈទំនាញ<br>២.១២- ម៉ាសទំនាញ និងម៉ាស និចលភាព<br>២.១៣- ភាពជោរ និងនាចរបស់ ទឹកសមុទ្រ<br>២.១៤- រណ្ដៅខ្មៅនិងអង្គធាតុខ្មៅ | សកល<br>- គណនាល្បឿន ខួប និងថាមពលមេកានិចរបស់រណប តាមគន្លងរង្វង់ បញ្ជាក់ច្បាប់កេប្លែរទាំងបី និងច្បាប់ទំនាញសកលរបស់ញូតុន<br>- បកស្រាយដំណើរការពីរណបដែលគេបង្កើតសម្រាប់ប្រើប្រាស់ស៊ីវិល ដូចជា GPS ជាដើម។<br>**ចរិយាសម្បទា**<br>- ទទួលបានចំណេះដឹងដ៏ពិសេសទាក់ទងនឹងការរកឃើញថ្មីរបស់វិទ្យាសាស្ត្រ ដែលនៅក្នុងប្រទេសខ្មែរយើង ក៏មានការយល់ច្រឡំផ្សេងៗទាក់ទងនឹងចក្កវាឡយើងនេះ។ | |
| **មេរៀនទី៣ : លំនឹងស្ដាទិច និងភាពយឺត**<br>៣.១- លក្ខខណ្ឌលំនឹង<br>៣.២- ផ្ចិតទំនាញ និងផ្ចិតម៉ាស<br>៣.៣-លក្ខណៈលំនឹងនៃអង្គធាតុរឹង<br>៣.៤- ច្បាប់ហ៊ុក<br>ម៉ូឌុលយ៉ាំង (Young's Modulus)<br>ម៉ូឌុលស៊ៀ (Shear modulus)<br>ម៉ូឌុលប៊ុក (Bulk Modulus) | **វិជ្ជាសម្បទា**<br>- ឱ្យនិយមន័យនៃម៉ូម៉ង់ឡើងវិញ<br>- ប្រាប់ពីទីតាំងនៃផ្ចិតម៉ាស និងទីប្រជុំទម្ងន់<br>- ពណ៌នាពីធ្នឹម<br>- ប្រាប់ពីនិយមន័យម៉ូឌុលនៃភាពយឺត។<br>**បំណិនសម្បទា**<br>- បង្ហាញពីភាពខុសគ្នាភាពយឺត និងភាពផ្លាស្ទិច<br>- បង្ហាញលក្ខខណ្ឌលំនឹងរបស់អង្គធាតុ<br>- កំណត់ផលគុណរវាងពីរ៉ិចទ័រ<br>- កំណត់ផលគុណរវាងពីរ៉ិចទ័រ<br>- បង្ហាញពីអត្ថន័យនៃ ស្រ្ដេស និងស្រ្ដេន<br>- បកស្រាយបានពីការទាញបានរូបមន្តៈ<br>-ម៉ូឌុលយ៉ាំង<br>-ម៉ូឌុលស៊ៀ<br>-ម៉ូឌុលប៊ុក។<br>**ចរិយាសម្បទា**<br>- មានស្មារតីប្រុងប្រយត្នពីការសាងសង់ស្ពាន ឬផ្ទះក្រោមលក្ខខណ្ឌលំនឹង។ | ៨ម៉ |
| **ជំពូក២ : ទែម៉ូឌីណាមិច** | | **២៤ម៉** |
| **មេរៀនទី១ : ទ្រឹស្ដីស៊ីនេទិចនៃឧស្ម័ន**<br>១.១- ទ្រឹស្ដីស៊ីនេទិចនៃឧស្ម័ន<br>១.២- សម្ពាធក្នុងទ្រឹស្ដីស៊ីនេទិចនៃឧស្ម័ន<br>១.៣- ថាមពលស៊ីនេទិចនៃឧស្ម័ន<br>១.៤- ឫសការេនៃល្បឿនការេមធ្យមរបស់ ឧស្ម័ន | **វិជ្ជាសម្បទា**<br>- ឱ្យទ្រឹស្ដីស៊ីនេទិចនៃឧស្ម័ន<br>- ឱ្យរូបមន្តថាមពលស៊ីនេទិចនៃឧស្ម័ន<br>- ឱ្យរូបមន្តឫសការេនៃល្បឿនការេមធ្យម។<br>**បំណិនសម្បទា**<br>- បកស្រាយនូវសម្ពាធរបស់ឧស្ម័នមានអំពើលើជញ្ជាំងធុង | ៦ម៉ |

| | | |
|---|---|---|
| | (តាមបរិមាត្រ)<br>- បកស្រាយថាមពលស៊ីនេទិចមធ្យមនៃមួយម៉ូលេគុលនៃឧស្ម័ន ហើយថាមពលស៊ីនេទិចមធ្យមសរុប<br>- បកស្រាយឫសការេនៃល្បឿនការេមធ្យមរបស់ម៉ូលេគុលនីមួយៗ<br>- អនុវត្តច្បាប់បិយ ច្បាប់សាល និងកេលុយសាក់ ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។<br>**ចរិយាសម្បទា**<br>- អភិវឌ្ឍចំណេះដឹងផ្នែកឧស្ម័នក្នុងជីវភាពរស់នៅដូចជា ស៊ីរ៉ាំងចាក់ថ្នាំ កង់ឡាន/ម៉ូតូ ធុងហ្គាស គ្រាប់កាំភ្លើង គ្រាប់បែក... | |
| **មេរៀនទី២ : ច្បាប់ទី១ទែម៉ូឌីណាមិច**<br>២.១- ប្រព័ន្ធទែម៉ូឌីណាមិច មជ្ឈដ្ឋានក្រៅ និងភាពនៃប្រព័ន្ធ<br>២.២- កងប្រព័ន្ធទែម៉ូឌីណាមិច<br>២.៣- ដ្យាក្រាមបង្ហាញពីភាពនៃទែម៉ូឌីណាមិច<br>២.៤- ករណីបំប្លែងបិទ-គោលការណ៍សមមូល<br>២.៥- លំនាំទែម៉ូឌីណាមិច លំនាំអ៊ីសូបា លំនាំអ៊ីសូករ លំនាំអ៊ីសូទែម លំនាំអាដ្យាបាទិច<br>២.៦- ថាមពលក្នុង និងច្បាប់ទី១ ទែម៉ូឌីណាមិច<br>២.៧- កាបញ្ជូនកម្តៅ និងកម្តៅម៉ាសនៃឧស្ម័នបរិសុទ្ធ | **វិជ្ជាសម្បទា**<br>- ពណ៌នាប្រព័ន្ធទែម៉ូឌណាម៉ិច<br>- ពណ៌នាពីសារៈសំខាន់នៃប្រព័ន្ធទែម៉ូឌីណាមិចនិងលំនាំទែម៉ូឌីណាម៉ិច<br>- ឱ្យនិយមន័យបំប្លែងបិទនិងបំប្លែងចំហ<br>- ឱ្យនិយមន័យច្បាប់ទី១ទែម៉ូឌីណាមិចបានច្បាស់លាស់<br>- រៀបរាប់ពីលំនាំទាំង៤នៃទែម៉ូឌីណាមិច<br>- រៀបរាប់ថាមពលក្នុងរបស់ឧស្ម័នបរិសុទ្ធអាស្រ័យតែសីតុណ្ហភាព<br>- រៀបរាប់ភាពខុសគ្នារវាងកម្តៅនៅមាឌប្រែប្រួលនិងសម្ពាធថេរ។<br>**បំណិនសម្បទា**<br>- បកស្រាយកម្មន្តនៃកម្លាំងរបស់ប្រព័ន្ធតាមផលគុណស្កាលែ<br>- បង្ហាញកម្មន្តនៃសម្ពាធថេរ កម្មន្តសម្ពាធប្រែប្រួលស្មើ និងកម្មន្តនៃសីតុណ្ហភាពថេរ តាមក្រាប<br>- សរសេរច្បាប់ទី១ទែម៉ូឌីណាមិច ព្រមទាំងបញ្ជាក់ទំហំពីជគណិតនីមួយៗ<br>- ពន្យល់របៀបគណនាកម្មន្តធ្វើដោយប្រព័ន្ធពេលមានវាប្រែប្រួលមាឌ សីតុណ្ហភាព និងសម្ពាធ<br>- វិភាគដ្យាក្រាមតាមលំនាំនៃបំប្លែងភាពនីមួយៗ<br>- បង្ហាញនូវការអនុវត្តនៃប្រព័ន្ធទែម៉ូឌីណាម៉ិចក្នុងជីវភាពរស់នៅនិងដំណើរការរបស់វា។<br>**ចរិយាសម្បទា**<br>- អភិវឌ្ឍចំណេះពីដំណើរការរបស់ប្រព័ន្ធទែម៉ូឌីណាមិចមួយដោយប្រើច្បាប់ទី១ទែម៉ូឌីណាមិចក្នុងជីវភាពរស់នៅដូចជា | ១០ម៉ |

| | | |
|---|---|---|
| | ការដាំទឹក ...។ | |
| **មេរៀនទី៣ : ច្បាប់ទី២ទែម៉ូឌីណាមិច**<br>**និងម៉ាស៊ីនកម្តៅ**<br>៣.១- លំនាំអាដ្យាបាទិច<br>៣.២- ច្បាប់ទី២ទែម៉ូឌីណាមិច<br>៣.៣- ម៉ាស៊ីនកម្តៅ និងស៊ិចកាណូ<br>សិចកាណូ និងទិន្នផលអតិបរមា<br>៣.៤- បំប្លែងបិទ និងបំប្លែងចំហ<br>៣.៥- ម៉ាស៊ីនសាំង និងម៉ាស៊ីនម៉ាស៊ូត<br>៣.៦- ទូទឹកកក ម៉ាស៊ីនត្រជាក់ និងម៉ាស៊ីន<br>កម្តៅ មេគុណបំពេញ COP<br>(Coefficient of Performance)<br>៣.៧- អង់ត្រូពី | **វិជ្ជាសម្បទា**<br>- រៀបរាប់លក្ខណៈនៃម៉ាស៊ីនចំហេះក្នុង និងម៉ាស៊ីនចំហេះក្រៅ<br>- រៀបរាប់ពីភាពខុសគ្នានៃម៉ាស៊ីនចំហេះក្នុងនិងម៉ាស៊ីនចំហេះក្រៅ<br>- រៀបរាប់ភាពខុសគ្នារវាងលំនាំផេស៊ីប និងអាំងផេស៊ីប<br>- រៀបរាប់ពីលក្ខណៈម៉ាស៊ីនសាំងនិងម៉ាស៊ីនម៉ាស៊ូត ព្រមទាំងភាពខុសគ្នា។<br>**បំណិនសម្បទា**<br>- បង្ហាញគោលការណ៍ម៉ាស៊ីនកម្តៅ ទូទឹកកក ម៉ាស៊ីនត្រជាក់ និងម៉ាស៊ីនកម្តៅ<br>- បង្ហាញទំនាក់ទំនងរវាងម៉ាស៊ីនត្រជាក់និងម៉ាស៊ីនកម្តៅ<br>- កំណត់ទិន្នផលម៉ាស៊ីន និង ការបង្កើតម៉ាស៊ីនត្រជាក់ ដោយប្រើច្បាប់ទី២ទែម៉ូឌីណាមិច<br>- កំណត់និយមន័យអង់ត្រូពីនិងរបៀបប្រើបញ្ញត្តិអង់ត្រូពី ដើម្បីវិភាគលំនាំទែម៉ូឌីណាម៉ិច<br>- គណនានូវទំនាក់ទំនងវដ្តកាកណូចំពោះម៉ាស៊ីនកម្តៅនិង ទូទឹកកក<br>- កំណត់អត្ថន័យនៃអង់ត្រូពី និងរបៀបប្រើបញ្ញត្តិនេះដើម្បីវិភាគ លំនាំទែម៉ូឌីណាម៉ិច<br>- សម្គាល់របៀបប្រើបញ្ញត្តិនៃមីក្រូស្កូពិកដើម្បីយល់នូវអង់ត្រូពី (ត្រូវរំលឹក ទំហំសីតុណ្ហភាព ថេរប៊ុលស្មាន់ លំនាំទែម៉ូឌី ណាម៉ិច ច្បាប់ទី១ទែម៉ូឌីណាម៉ិច ការរីកនៃឧស្ម័ន)។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីក្នុងការស្រាវជ្រាវផ្នែកម៉ាស៊ីន<br>- អភិវឌ្ឍចំណេះដឹងជាមូលដ្ឋានគ្រឹះផ្នែកម៉ាស៊ីនដើម្បីសិក្សាបន្ត ផ្នែកមេកានិចនៅមហាវិទ្យាល័យ។ | ៨ម៉ |
| **ជំពូកទី៣ : រលក** | | **២០ម៉** |
| **មេរៀនទី១ : រលកមេកានិច**<br>១.១- ប្រភេទរលក<br>១.២- ជំហានរលក ប្រេកង់ និងល្បឿន<br>ដំណាលនៃរលក<br>១.៣- ចំណាំផ្លាតនៃរលក<br>១.៤- សមីការរលកស៊ីនុយសូអ៊ីត<br>១.៥- ល្បឿនដំណាលរលកលើខ្សែល្បឿន<br>សម្លេង និងល្បឿនរលកទឹក | **វិជ្ជាសម្បទា**<br>- ឱ្យនិយមន័យទូទៅនៃរលក<br>- ឱ្យនិយមន័យរលកបណ្តោយនិងរលកទទឹងបានច្បាស់លាស់<br>- ប្រាប់និយមន័យល្បឿនដំណាលនៃរលក និងរូបមន្តរបស់វា។<br>**បំណិនសម្បទា**<br>- បង្ហាញពីទំនាក់ទំនងនៃ ពុលសាស្យុង ខួប ប្រេកង់ ល្បឿនរលក ជំហ៊ានរលក<br>- បង្ហាញពីថាមពលបញ្ជូនក្នុងរលកមេកានិច | ១០ម៉ |

| | | |
|---|---|---|
| ១.៦- ថាមពលនៃរលក | - បង្ហាញពីអានុភាពបញ្ជូនក្នុងរលកមេកានិច<br>- បង្ហាញពីអានុភាពបញ្ជូនក្នុងមួយខ្នាតផ្ទៃ(អាំងតង់ស៊ីតេបញ្ជូន) នៃរលកមេកានិច<br>- បកស្រាយសមីការរលកអនុគមន៍នៃពេល (ដាលតាមទិសដៅវិជ្ជមាន) និងសមីការរលកដាលត្រឡប់ (ដាលតាមទិសដៅអវិជ្ជមាន)<br>- គណនាអេឡុចកាស្យុងនៃរលកជាអនុគមន៍នៃពេល។<br>**ចរិយាសម្បទា**<br>- អភិវឌ្ឍចំណេះដឹងអំពីរលកបណ្តោនិងរលកទទឹង ព្រមការអនុវត្តក្នុងជីវភាពប្រចាំថ្ងៃដូច រលកទឹក រលកខ្សែ រញ្ជួយដី រលកសូរ ...។ | |
| **មេរៀនទី២ : រលកតម្រួត**<br>២.១- គោលការណ៍តម្រួតនៃរលក<br>២.២- លក្ខខណ្ឌព្រំដែននៃរលក (Boundary conditions)<br>២.៣- រលកជញ្ជ្រុំលើខ្សែ<br>២.៤- រលកជញ្ជ្រុំរបស់សូរ ថ្នាំងនៃសូរ និងឧបករណ៍ភ្លេង (ខ្លុយ ហ្វូត...)<br>២.៥- អាំងទែផេរ៉ង់សូរ<br>២.៦- អាំងទែផេរ៉ង់ពន្លឺ<br>- គោលការណ៍តម្រួតនិងអាំងទែផេរ៉ង់<br>- ពិសោធន៍រង្វះ២របស់ថូម៉ាសយ៉ាំង<br>- របាយអាំងតង់ស៊ីតេនៃអាំងទែផេរ៉ង់រង្វះមួយ និងពីរ<br>២.៧- សន្ទស្សន៍នៃចំណាំងបែរ ល្បឿនពន្លឺ និងកូអេរ៉ង់នៃរលក<br>២.៨- ងទេផេរ៉ង់<br>២.៩- អានុភ្យុង<br>២.១២- ប៉ូលកម្មនៃរលកពន្លឺ | **វិជ្ជាសម្បទា**<br>- ពណ៌នាច្បាស់លាស់នូវគោលការណ៍តម្រួតនៃរលក<br>- ប្រាប់ពីលក្ខណៈ លក្ខខណ្ឌដំណាលរលក អំព្លីទុត និងផាសនៃរលក<br>- ពណ៌នាច្បាស់លាស់នូវទំនាក់ទំនងបាតុភូតអាំងទែផេរ៉ង់ និងបាតុភូតឌីប្រាក់ស្យុងនៃតម្រួតរលកពីរ<br>- ពណ៌នានូវបាតុភូតរលកជញ្ជ្រុំដែលកើតឡើងក្នុងជីវភាពរស់នៅ<br>- បង្ហាញពីពិសោធន៍យ៉ាំង។<br>**បំណិនសម្បទា**<br>- បកស្រាយសមីការរលកតម្រួត រលកជញ្ជ្រុំ និងអាំងទែផេរ៉ង់<br>- បកស្រាយផលសងដំណើរនៃអាំងទែផេរ៉ង់មេកានិច<br>- បកស្រាយទីតាំងប្រង់ភ្លឺ និងទីតាំងប្រង់ងងឹត<br>- បកស្រាយចន្លោះប្រង់<br>- ពិសោធ៖ រលកជញ្ជ្រុំ និងពិសោធរង្វះពីរយ៉ុង<br>- អនុវត្តលំហាត់រលកតម្រួត រលកជញ្ជ្រុំ អាំងទែផេរ៉ង់មេកានិច អាំងទែផេរ៉ង់ពន្លឺ និងអាំងទែផេរ៉ង់សូរ<br>- បង្ហាញពីដំណើរការរបស់ CD ឬ DVD នៃគោលការណ៍អាំងតែផេរ៉ង់ពន្លឺ<br>- បង្ហាញពីការដំណើរការនៃ ស្នៀតខ្យល់(Air Wedge) ចិញ្ចៀនញូតុន (Newton′s Rings)។<br>**ចរិយាសម្បទា**<br>- អភិវឌ្ឍចំណេះដឹងអំពីដំណើរការ CD ឬ DVD ដែលជាបាតុភូតអាំងទែផេរ៉ង់ពន្លឺ<br>- អភិវឌ្ឍចំណេះដឹងពីដំណើរការរបស់ឧបករណ៍ភ្លេងមួយចំនួន។ | ១០ម៉ |

| ជំពូក៤ : ម៉ាញេទិច | | ៣៦ម៉ |
| --- | --- | --- |
| **មេរៀនទី១ : អាំងឌុចស្យុងអេឡិចត្រូម៉ាញេទិច**<br>១.១- ច្បាប់ផារ៉ាដេនៃអាំងឌុចស្យុង<br>១.២- អគ្គិសនីចលករអាំងឌុី<br>១.៣- ចរន្តអែឌី(ឬចរន្តភូកូល)<br>១.៤- ជនិតា និងម៉ូទ័រអគ្គិសនី | **វិជ្ជាសម្បទា**<br>- ពណ៌នាពិសោធន៍ទី១ និងទី២ ផារ៉ាដេ<br>- ប្រាប់ពីបាតុភូតដែលធ្វើឱ្យកើតមានចរន្តនិងប្រភេទចរន្តក្នុងបូប៊ីននៃពិសោធន៍ផារ៉ាដេ<br>- ឱ្យរូបមន្តភ្លុចម៉ាញេទិច<br>- ប្រាប់ពីច្បាប់ឡិនទី១ និងទី២<br>- ពណ៌នាទំនាក់ទំនងរវាងកម្លាំងអគ្គិសនីអូតូអាំងឌុចស្យុងនិងបម្រែបម្រួលចរន្តអាស្រ័យនឹងពេល<br>- ប្រាប់ពីការគូសខ្សែដែនម៉ាញេទិចនិងកម្លាំងម៉ាញេទិចបានច្បាស់លាស់។<br>**បំណិនសម្បទា**<br>- បង្ហាញចរន្តអេឌីកើនឡើងក្នុងលោហៈពេលមានចលនាក្នុងដែនម៉ាញេទិច<br>- ស្រាយបញ្ជាក់នូវកម្លាំងអគ្គិសនីចលករអាំងឌុីដែលកើតមានខណៈមានបម្រែបម្រួលភ្លុចម៉ាញេទិចឆ្លងកាត់ផ្ទៃមុខកាត់នៃបូប៊ីន<br>- ធ្វើពិសោធន៍ច្បាប់ផារ៉ាដេ និងច្បាប់ឡិនដោយធ្វើពិសោធន៍បង្ហាញនូវរបៀបកំណត់ទិសដៅនៃចរន្តអាំងឌុីក្នុងសៀគ្វី<br>- បកស្រាយនូវអាំងឌុចតង់នៃបូប៊ីនមួយ<br>- ពន្យល់ពីដំណើរការនៃជនិតាចរន្តឆ្លាស់ និងម៉ូទ័រអគ្គិសនីព្រមទាំងភាពខុសគ្នា<br>- ស្រាយបញ្ជាក់នូវកម្លាំងអគ្គិសនីចលករអាំងឌុីជាអនុគមន៍នៃផ្ទៃមុខកាត់បូប៊ីន ល្បឿនមុំ និងពេល។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីយល់ដឹងអំពីភាពផ្ទុយគ្នានៃដំណើរការរបស់ម៉ូទ័រនិងជនិតាចរន្តឆ្លាស់ ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ<br>- អភិវឌ្ឍចំណេះដឹងលើបាតុភូតអាំងឌុចស្យុងអេឡិចត្រូម៉ាញេទិចនិងដំណើរការផលិតថាមពលអគ្គិសនីចរន្តឆ្លាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ | ៨ម៉ |
| **មេរៀនទី២ : អាំងឌុចស្យុង**<br>២.១- អំពើទៅវិញទៅមករបស់អាំងឌុចស្យុង<br>២.២- អូតូអាំងឌុចស្យុង<br>២.៣- កម្លាំងអគ្គិសនីចលករអូតូអាំងឌុី<br>២.៤- ថាមពលម៉ាញ៉េទិច | **វិជ្ជាសម្បទា**<br>- ឱ្យទំនាក់ទំនងភ្លុចម៉ាញេទិចនិងអាំងឌុចតង់នៃសៀគ្វី<br>- ពណ៌នាចរន្តប្រែប្រួលអាស្រ័យនឹងពេលក្នុងបូប៊ីនអាចបង្កើតកម្លាំងអគ្គិសនីចលករអាំងឌុីក្នុងរបុំមធ្យម<br>- ពណ៌នាទំនាក់ទំនងកម្លាំងអគ្គិសនីចលករអាំងឌុីក្នុងសៀគ្វីអាស្រ័យនឹងបម្រែបម្រួលចរន្តក្នុងសៀគ្វីដូចគ្នា។ | ១០ម៉ |

| | | |
|---|---|---|
| ២.៥- សៀគ្វី *RL*<br>២.៦- លំយោលក្នុងសៀគ្វីយោល *LC* | **បំណិនសម្បទា**<br>- បង្ហាញពីហេតុផលនៃលំយោលអគ្គិសនីកើតមានក្នុងសៀគ្វីជាមួយដែលមានបង្គុំនៃ បូប៊ីននិងកុងដង់សាទ័រ និងរេស៊ីស្តរ<br>- បង្ហាញពីហេតុផលនៃលំយោលអគ្គិសនីកើតមានក្នុងសៀគ្វីជាមួយដែលមានបង្គុំនៃ បូប៊ីន និងកុងដង់សាទ័រ<br>- បង្ហាញពីគោលការណ៍អាំងឌុចស្យុងនៅក្នុងត្រង់ស្វូបានត្រឹមត្រូវ<br>- វិភាគសៀគ្វីនៃបង្គុំ រេស៊ីស្តរ និងអាំងឌុចទ័រ (បាតុភូតអូតូអាំងឌុចស្យុងពេលសៀគ្វីបិទ)<br>- កំណត់កន្សោមកម្លាំងអគ្គិសនីចលករអូតូអាំងឌ្វីខណៈ<br>- កំណត់កន្សោមរូបមន្តថាមពលម៉ាញេទិច<br>- កំណត់បានច្បាស់លាស់នូវតង់ស្យុងគោលនៃសៀគ្វីសេរី និងខ្នែង *RL*<br>- កំណត់ថេរពេលនៃសៀគ្វី RL<br>- កំណត់កន្សោមចរន្តខណៈក្នុងសៀគ្វី RL<br>- វិភាគបន្ទូរថាមពលក្នុងសៀគ្វី LC<br>- បង្ហាញ កន្សោមតង់ស្យុងខណៈ បន្ទុកខណៈ និងចរន្តខណៈក្នុងលំយោលសៀគ្វី LC<br>- គណនាកម្លាំងអគ្គិសនីចលករអាំងឌ្វីក្នុងអង្គធាតុចម្លងពេលផ្លាស់ទីឆ្លងកាត់ដែនម៉ាញេទិច<br>- ធ្វើពិសោធន៍សៀគ្វី RL តាមបែបគុណភាព។<br>**ចរិយាសម្បទា**<br>- អភិវឌ្ឍចំណេះដឹងអំពីការកើតឡើងនៃចរន្តអគ្គិសនីអាំងឌ្វីក្នុងបូប៊ីន ខណៈភ្លុចម៉ាញេទិចឆ្លងកាត់វា ក្នុងបច្ចេកទេស<br>- អភិវឌ្ឍចំណេះដឹងជាមូលដ្ឋានគ្រឹះដើម្បីសិក្សាជំនាញនៅមហាវិទ្យាល័យ។ | |
| **មេរៀនទី៣ : សៀគ្វីចរន្តឆ្លាស់**<br>៣.១- ប្រភពចរន្តឆ្លាស់<br>៣.២- រេស៊ីស្តរក្នុងចរន្តឆ្លាស់<br>៣.៣- អាំងឌុចទ័រក្នុងចរន្តឆ្លាស់<br>៣.៤- កុងដង់សាទ័រក្នុងចរន្តឆ្លាស់<br>៣.៥- សៀគ្វី RLC ជាស៊េរី<br>៣.៦- អានុភាពក្នុងសៀគ្វីចរន្តឆ្លាស់<br>៣.៧- រេសូណង់សៀគ្វី RLC ជាស៊េរី<br>៣.៨- ត្រង់ស្វូ និងការបញ្ជូនថាមពល<br>៣.៩- សម្ងួយចរន្តឆ្លាស់ | **វិជ្ជាសម្បទា**<br>- ឱ្យនិយមន័យចរន្តឆ្លាស់<br>- ឱ្យនិយមន័យសម្ងួយចរន្តឆ្លាស់<br>- ពណ៌នាចរន្តឆ្លាស់អនុគមន៍នឹងតង់ស្យុងនិងចរន្តអាស្រ័យពេល<br>- ប្រាប់ពីកន្សោមអាំងតង់ស៊ីតេចរន្តឆ្លាស់ ខ្ពប និងប្រេកង់<br>- ស្គាល់នូវអានុភាពមធ្យមនិងកត្តាអានុភាព<br>- ស្គាល់ត្រង់ស្វូម៉ាទ័រនិងដំណើរការរបស់វា<br>- ស្គាល់នូវគោលការណ៍សម្ងួយចរន្តឆ្លាស់។ | ១២ម៉ |

| | | |
|---|---|---|
| | **បំណិនសម្បទា**<br>- បង្ហាញពីអានុភាពខាតបង់ក្នុងត្រង់ស្វូ<br>- បង្ហាញពីវិធីបង្ការគ្រោះថ្នាក់នៃការឆក់ចរន្តអគ្គិសនី<br>- បង្ហាញពីផលទាំងបីនៃចរន្តឆ្លាស់<br>- កំណត់កន្សោមចរន្តឆ្លាស់ខណៈ<br>- បង្ហាញពីតង់ស្យុងគោលខណៈគ្រឿងទទួលជា កុងឌុចទ័រ រេស៊ីស្តរ និងជាកុងដង់សាទ័រ<br>- កំណត់កន្សោមអាំប៉េដង់នៃសៀគ្វីជា រេស៊ីស្តង់ កុងដង់សាទ័រ និងអាំងឌុចទ័រ<br>- បង្ហាញពីតង់ស្យុងប្រសិទ្ធនៃ កុងឌុចទ័រ រេស៊ីស្តរ និងជាកុងដង់សាទ័រ<br>- កំណត់កន្សោមចរន្តខណៈនៃ រេស៊ីស្តរ កុងឌុចទ័រ និងជាកុងដង់សាទ័រ ព្រមទាំងគូសក្រាបតាងចរន្តនិងតង់ស្យុងខណៈជាអនុគមន៍នៃពេល<br>- កំណត់ស្យុងខណៈនៃសៀគ្វី RLC<br>- កំណត់កន្សោមអាំប៉េដង់សមមូលនៃសៀគ្វី RLC<br>- ធ្វើគំនូសបំព្រួញសំណង់ប្រេណែលនៃសៀគ្វី RLC<br>- កំណត់អានុភាពមធ្យមនៃសៀគ្វីចរន្តឆ្លាស់<br>- បង្ហាញពីលក្ខណៈ មុខងារ និងទិន្នផលនៃត្រង់ស្វូ<br>- បញ្ជាក់លក្ខណៈរេសូណង់នៃសៀគ្វី RLC និងប្រេកង់រេសូណង់<br>- ពន្យល់ពីមុខងាររបស់ត្រង់ស្វូ និងផលធៀបបំប្លែងបានច្បាស់លាស់<br>- ពន្យល់ពីអាំងតង់ស៊ីតេចរន្តប្រសិទ្ធនិងតង់ស្យុងប្រសិទ្ធ<br>- គណនាតង់ស្យុង ចរន្ត និងចំនួនស្ពៀដែលមានទំនាក់ទំនងគ្នា<br>- អនុវត្តត្រង់ស្វូក្នុងជីវភាពរស់នៅប្រចាំថ្ងៃ<br>- ពិសោធសៀគ្វី RLC។<br>**ចរិយាសម្បទា**<br>- អភិវឌ្ឍចំណេះដឹងលើ មុខងារត្រង់ស្វូ គោលការណ៍សម្ងួយ និងគោលការណ៍បន្លែងចរន្តឆ្លាស់ទៅជាចរន្តជាប់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ | |
| **មេរៀនទី៤ : រលកអេឡិចត្រូម៉ាញេទិច**<br>៤.១- បម្រែបម្រួលដែនអគ្គិសនី ការបង្កើតដែនម៉ាញេទិច<br>៤.១- សមីការ Maxwell | **វិជ្ជាសម្បទា**<br>- ពិណ៌នានូវទំនាក់ទំនងរវាងបាតុភូតអគ្គិសនីនិងម៉ាញេទិចរបស់លោក Maxwell (ទ្រឹស្ដី៤ទាក់ទងគ្នា)<br>- បញ្ជាក់ពីការបកស្រាយរបស់លោក Hertz លើទ្រឹស្ដីស្ដី | ៦ម៉ |

| | | |
|---|---|---|
| ៤.២- ការបង្កើតរលកអេឡិចត្រូម៉ាញេទិច និងស្ប៉ិចអេឡិចត្រូម៉ាញេទិច<br>៤.៣- ការវាស់ល្បឿនពន្លឺ<br>៤.៤- ថាមពលក្នុងរលកអេឡិចត្រូម៉ាញេទិច<br>៤.៥- បរិមាណចលនាបញ្ជូន និង សម្ពាធផ្សាយ<br>៤.៥- វិទ្យុនិងទូរទស្សន៍ និងទូរគមនាគមន៍ឥតខ្សែ | Maxwell<br>អំពីការបញ្ជូនថាមពលពីអង្គធាតុបញ្ជូនទៅអង្គធាតុទទួល ក្នុងទម្រង់ជារលកអេឡិចត្រូម៉ាញេទិច<br>- បង្ហាញពីការបង្កើតរលកអេឡិចត្រូម៉ាញេទិចនិងស្ប៉ិចម៉ាញេទិច<br>- ពន្យល់ពីហេតុផលដែលរលកពន្លឺមានទំនាក់ទំនងទៅនឹងថេរគ្រឹះនៃអគ្គិសនី និងម៉ាញេទិច<br>- បង្ហាញថា រលកអេឡិចត្រូម៉ាញេទិចជារលកស៊ីនុយសូអ៊ីត<br>- ឱ្យនិយមន័យរលកអេឡិចត្រូម៉ាញេទិច<br>- បញ្ជាក់អំពីលក្ខណៈដំណាលនៃរលកអេឡិចត្រូម៉ាញេទិច<br>- បង្ហាញពីការវាស់ល្បឿនពន្លឺ<br>- ឱ្យទំនាក់ទំនងល្បឿន ប្រេកង់ និងជំហានរលក នៃរលកអេឡិចត្រូម៉ាញេទិច<br>- កំណត់នូវថាមពលក្នុងរលកអេឡិចត្រូម៉ាញេទិច<br>- កំណត់នូវបរិមាណចលនាបញ្ជូននិងសម្ពាធផ្សាយ<br>- ឱ្យនិយមន័យ រលកវិទ្យុ រលកខ្លី រលកអាំងប្រារ៉ូ ពន្លឺមើលឃើញ ពន្លឺស្វាយអ៊ុលត្រា កាំរស្មី X និងកាំរស្មីហ្គាម៉ា។<br>**បំណិនសម្បទា**<br>- បកស្រាយពីលក្ខណៈនៃរលកអេឡិចត្រូម៉ាញេទិច<br>- កំណត់នូវទំនាក់ទំនងរវាងដែនម៉ាញេទិច ដែនអគ្គិសនី និងល្បឿនពន្លឺ $c = \frac{E}{B} = \lambda f$<br>- កំណត់អាំងតង់ស៊ីតេមធ្យមនៃរលកអេឡិចត្រូម៉ាញេទិច $\bar{I} = \frac{1}{2}\varepsilon_0 c E_0^2 = \frac{1}{2}\frac{c}{\mu_0}B_0^2 = \frac{1}{2}\frac{E_0 B_0}{\mu_0}$<br>- កំណត់បរិមាណចលនាបញ្ជូនរលកអេឡិចត្រូម៉ាញេទិច $\Delta p = \frac{\Delta U}{c}$<br>- បង្ហាញថាសម្ពាធបញ្ជូន $P = \frac{2\bar{I}}{c}$ ។<br>**ចរិយាសម្បទា**<br>- អភិវឌ្ឍចំណេះដឹងលើរលកអេឡិចត្រូម៉ាញេទិចនៃការបញ្ជូន និងទទួលនៃវិទ្យុនិងទូរទស្សន៍ និងដំណើរការនៃទូរគមនាគមន៍ឥតខ្សែ ក្នុងបច្ចេកវិទ្យានិងជីវភាពរស់នៅប្រចាំថ្ងៃ។ | |

| | | |
|---|---|---|
| **ជំពូក៥ : រូបវិទ្យាទំនើបមេកានិច** | | **៣២ម៉** |
| **មេរៀនទី១ : គ្រឿងអេឡិចត្រូនិច**<br>១.១- ការចម្លងនៃអង្គធាតុរឹង<br>១.២- ទ្រឹស្តីចងសម្ព័ន្ធនៃអង្គធាតុរឹង<br>១.៣- គ្រឿងអេឡិចត្រូនិច ឌីយ៉ូត ត្រង់ស៊ីស្ទ័រ និងអ៊ីសេ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីភាពខុសគ្នារវាងលោហៈ  សឺមីកុងឌុចទ័រ និងអ៊ីសូឡង់បានយ៉ាងត្រឹមត្រូវ<br>- បង្ហាញពីប្រភេទអង្គធាតុរឹង<br>- ពណ៌នាអំពីចលនាគ្មានសណ្តាប់ធ្នាប់របស់អេឡិចត្រុងសេរី និងឥទ្ធិពលរបស់វា<br>- រៀបរាប់ពីអង្គធាតុចម្លង  អ៊ីសូឡង់ សឺមីកុងឌុចទ័រ<br>- បង្ហាញពីទម្រង់អាតូម និងទ្រឹស្តីបទប៊របានត្រឹមត្រូវ<br>- បង្ហាញពីធាតុមិនសុទ្ធក្នុងអង្គធាតុរឹង<br>- ឱ្យនិយមន័យសឺមីកុងឌុចទ័រ ឌីយ៉ូ និងត្រង់ស៊ីស្ទ័របានត្រឹមត្រូវ។<br>**បំណិនសម្បទា**<br>- ពន្យល់លក្ខណៈគ្រឹះនៃសឺមីកុងឌុចទ័រ ប្រភេទ(p និង n) និងផ្នែកខាងក្នុងបានត្រឹមត្រូវ<br>- ពន្យល់ពីឌីយ៉ូត  ត្រង់ស៊ីស្ទ័រ និងអ៊ីសេ<br>- ពន្យល់បានច្បាស់លាស់អំពីប្រភេទអង្គធាតុរឹងនិមួយៗ<br>- ពន្យល់ពីទ្រឹស្តីបទ Band Theory នៃអង្គធាតុរឹង<br>- ពន្យល់លក្ខណៈ ឌីយ៉ូត ប្រភេទឌីយ៉ូត និងផ្នែកខាងក្នុងបានត្រឹមត្រូវ<br>- ពន្យល់លក្ខណៈត្រង់ស៊ីស្ទ័រ ប្រភេទ និងផ្នែកខាងក្នុងបានត្រឹមត្រូវ<br>- ពន្យល់លក្ខណៈអ៊ីនធីក្រេតសៀគ្វី (IC) ប្រភេទ និងផ្នែកខាងក្នុងបានត្រឹមត្រូវ<br>- ពណ៌នាពីលក្ខណៈនៃប្រភេទឌីយ៉ូត ត្រង់ស៊ីស្ទ័រ IC និងគំនូសតាងលក្ខណៈចរន្ត-តង់ស្យុងរបស់វាក្នុងសៀគ្វីអគ្គិសនី។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីប្រុងប្រយត្នក្នុងការប្រើប្រាស់ឌីយ៉ូតដើម្បីបំប្លែងចរន្តឆ្លាស់ទៅជាចរន្តជាប់<br>- បណ្តុះស្មារតីប្រុងប្រយត្នក្នុងការប្រើប្រាស់ត្រង់ស៊ីស្ទ័រមានមុខងារជាកុងតាក់ និងពង្រីកស៊ីញ៉ាល់(បង្កើនចរន្តអគ្គិសនី)<br>- បណ្តុះស្មារតីប្រុងប្រយត្នក្នុងការប្រើប្រាស់ឌីយ៉ូត ត្រង់ស៊ីស្ទ័រ IC ក្នុងជីវភាពប្រចាំថ្ងៃ<br>- អភិវឌ្ឍចំណេះដឹងជាមូលដ្ឋានគ្រឹះដើម្បីចាប់ជំនាញផ្នែក | ៦ម៉ |

| | | |
|---|---|---|
| | អគ្គិសនីនៅមហាវិទ្យាល័យ។ | |
| **មេរៀនទី២ : ទ្រឹស្ដីកង់ទិច និងទម្រង់អាតូម**<br>២.១-ការរកឃើញ និងលក្ខណៈនៃអេឡិចត្រុង<br>២.២- ការបន្សាយនៃអង្គធាតុខ្មៅ និងតេស្តកង់ទិចរបស់លោកប្លង់<br>២.៣- ទ្រឹស្ដីផូតុងនៃពន្លឺ និងផលផូតូអគ្គិសនី<br>២.៤- ថាមពល ម៉ាស និងម៉ូម៉ង់នៃផូតុង<br>២.៥- ផលកំតុង<br>២.៦- រលក-លំយោលផង់ពីរ គោលការណ៍បំពេញគ្នា<br>២.៧- ធម្មជាតិរលកនៃភាគល្អិត<br>២.៨- មីក្រូស្កុបអេឡិចត្រុង<br>២.៩- គម្រូអាតូមដំបូង<br>២.១០- គម្រូប៊ រ | **វិជ្ជាសម្បទា**<br>- ពិពណ៌នានូវសម្ព័ន្ធអាតូម និងសម្ព័ន្ធរងនៃរូបធាតុទាំងអស់<br>- ពិពណ៌នាពីរបៀបដែលអេឡិចត្រុងត្រូវបានរកឃើញ<br>- ពន្យល់ពីការពិសោធនៃតំនក់ប្រេង Millikan ដើម្បីទទួលបានម៉ាសពីតម្លៃរង្វាស់ផលធៀបនៃ $e/m$<br>- ពណ៌នាពីការវាស់បន្ទុករបស់អេឡិចត្រុង<br>- បង្ហាញពីការរកឃើញអេឡិចត្រុងដោយបំពង់កាំរស្មីកាតូត (cathode ray tube)<br>- បង្ហាញពីការបំភាយកម្តៅនិងរអេឡិចត្រូម៉ាញេទិចរបស់អង្គធាតុខ្មៅ<br>- ឱ្យទំនាក់ទំនងជំហ៊ានរលកនៃពន្លឺនិងសីតុណ្ហភាព $\lambda_p T = 2.90\times10^{-3}\,\mathrm{m.K}$<br>- ឱ្យរូបមន្តថាមពលលំយោលរបស់អាតូមជុំវិញម៉ូលេគុល $E = hf$<br>- ឱ្យរូបមន្តថាមពលលំយោលម៉ូលេគុលសរុប $E = nhf$<br>- កំណត់ម៉ូម៉ង់របស់ផូតុង $p = \frac{E}{c} = \frac{hf}{c} = \frac{h}{\lambda}$<br>- ពណ៌នាអំពីពិសោធន៍ផលផូតូអគ្គិសនី<br>- ពណ៌នានូវទ្រឹស្ដីផូតុងនៃពន្លឺ<br>- កំណត់ថាមពលស៊ីនេទិចអតិបរមារបស់ផូតូអេឡិចត្រុងដាច់ចេញដោយផូតុងនៃថាមពល ឬជំហ៊ានរលក ពេលថាមពលស៊ីនេទិចអតិបរមារបស់ផូតូអេឡិចត្រុងទាំងឡាយសម្រាប់ថាមពលឬជំហ៊ានរលកផូតុងខុសគ្នា។<br>- អនុវត្តផូតូអគ្គិសនីក្នុង កន្លឹងពោទ៍ និងទ្វារបិទបើកស្វ័យប្រវត្តិ<br>- បង្ហាញពីផលកំតុងនិងជំហ៊ានរលកបន្ទាប់ពីមានចំណាំងផ្លាតនៃពន្លឺ $\lambda' = \lambda + \frac{h}{m_e c}(1-\cos\phi)$<br>- បង្ហាញពីដំណើរការមីក្រូស្កុបអេឡិចត្រុង<br>- បង្ហាញពីគម្រូអាតូមដំបូងដោយពិសោធន៍របស់លោករូថ័រហ្វត<br>- ពិពណ៌នាអំពីអាថ៌កំបាំងនៃស្បិចអាតូម<br>- ពន្យល់ទ្រឹស្ដីប៊ រនៃអាតូមអ៊ីដ្រូសែន<br>- បង្ហាញពីថាមពលនៃអាតូមអ៊ីដ្រូសែន<br>- បង្ហាញអំពីការពិសោធប៊ រ។ | ៨ម៉ |

| | | |
|---|---|---|
| | **បំណិនសម្បទា**<br>- ពន្យល់ពីរបៀបនៃការរកឃើញអេឡិចត្រុង និងណ្វៃយ៉ូ<br>- ពន្យល់ទម្រង់អាតូមរបស់លោកប៊រ។<br>**ចរិយាសម្បទា**<br>- អភិវឌ្ឍចំណេះដឹងលើការអនុវត្តកាំរស្មីឡាស៊ែរក្នុងវេជ្ជសាស្ត្រ និងផលប៉ះពាល់ក្នុងជីវភាពប្រចាំថ្ងៃ។ | |
| **មេរៀនទី៣ : ថាមពលនុយក្លេអ៊ែរ ប្រសិទ្ធភាពនិងការប្រើប្រាស់កាំរស្មី**<br>៣.១- ការចងសម្ព័ន្ធនិងលក្ខណៈណ្វៃយ៉ូ<br>៣.២- ការបំបែកនុយក្លេអ៊ែរ និងប្រតិកម្មនុយក្លេអ៊ែរ<br>៣.៣- សកម្មភាពវិទ្យុសកម្ម<br>៣.៤- ការបន្សាយភាគល្អិត អាល់ហ្វា បែតា និងហ្គាម៉ា<br>៣.៥- ពាក់កណ្តាលជីវិតនិងអត្រាបន្សាយ<br>៣.៦- ការព្យាបាលដោយកាំរស្មី<br>៣.៧- ការបន្សាយតូម៉ូហ្គ្រាហ្វី៖ PET និង SPECT<br>៣.៨- រេសូណង់ម៉ាញេទិចនុក្លេអ៊ែ (NMR) និងរូបភាពរេសូណង់ម៉ាញេទិច (MRI) | **វិជ្ជាសម្បទា**<br>- ឱ្យនិយមន័យអំពីណ្វៃយ៉ូនៃអាតូមមួយ<br>- ឱ្យនិយមន័យ ប្រតិកម្មនុយក្លេអ៊ែរ<br>- ឱ្យគម្រូសមីការប្រតិកម្មនុយក្លេអ៊ែរ<br>- ឱ្យនិយមន័យការបំបែកនុយក្លេអ៊ែរ និងប្រតិកម្មនុយក្លេអ៊ែរ<br>- បង្ហាញគោលការណ៍និងដំណើការរបស់ Reactor នុយក្លេអ៊ែរ<br>- ឱ្យនិយមន័យ វិទ្យុសកម្មបានត្រឹមត្រូវ<br>- ឱ្យនិយមន័យ ពាក់កណ្តាលជីវិត។<br>**បំណិនសម្បទា**<br>- កំណត់នូវលក្ខណៈណ្វៃយ៉ូនៃអាតូមមួយ<br>- កំណត់ចំនួនអាតូមិច<br>- កំណត់និងពិភាក្សាអំពីអ៊ីសូតូប<br>- ថ្លឹងសមីការប្រតិកម្មនុយក្លេអ៊ែរ<br>- ពន្យល់អំពីបន្សាយនុយក្លេអ៊ែរ<br>- ពន្យល់ប្រភេទបន្សាយដូចជា បន្សាយអាល់ហ្វា បន្សាយប៊ែតា បន្សាយហ្គាម៉ា<br>- ពន្យល់ពីការអនុវត្តរោងចក្រអគ្គិសនីដើរដោយថាមពលនុយក្លេអ៊ែ<br>- កំណត់អាយុកាលរបស់អង្គធាតុផ្សេងៗ<br>- បង្ហាញពីការព្យាបាលដោយកាំរស្មី<br>- ពិពណ៌នាពីបច្ចេកទេសថតរូប PET និង SPECT<br>- ពិពណ៌នាអំពីបាតុភូតនិងបច្ចេកទេសវេជ្ជសាស្ត្រ NMR និង MRI។<br>**ចរិយាសម្បទា**<br>- អភិវឌ្ឍចំណេះពីការព្យាបាលជម្ងឺមហារីកដោយកាំរស្មី ការថត3D នៃប្រភេទ PET - SPET - MRI និង CT ស្កែន ជាដើមក្នុងវេជ្ជសាស្ត្រ។<br>- បណ្តុះចំណេះដឹងជាមូលដ្ឋានគ្រឹះសម្រាប់សិក្សាជំនាញផ្នែកបច្ចេកទេសវេជ្ជសាស្ត្រ ឬបរិទ្យាវេជ្ជសាស្ត្រនៅថ្ងៃអនាគត។ | ១០ម៉ |

| | | |
|---|---|---|
| **មេរៀនទី៤ : លក្ខណៈនៃផង់**<br>៤.១- ផង់មានថាមពលខ្ពស់<br>និងបន្ទប់ពន្លឿន<br>៤.២- ការកកើតនៃផង់<br>៤.៣- ផង់និងមិនមែនផង់<br>៤.៤- អន្តរកម្មរវាងផង់ និងច្បាប់រក្សា<br>៤.៥- ណឺទ្រីណូ<br>៤.៦- ក្វាក | **វិជ្ជាសម្បទា**<br>- ឱ្យនិយមន័យបន្ទប់ពន្លឿនផង់<br>- ប្រាប់ពីថាមពលខ្ពស់នៃផង់<br>- ឱ្យទំនាក់ទំនងជំហានរលក ថេរប្លង់ និងបរិមាណចលនារបស់រូបមន្ត de Broglie<br>- ឱ្យនិយមន័យណឺទ្រីណូ<br>- ពិពណ៌នាក្វាកនិងមិនមែនក្វាក<br>- សង្ខេបលក្ខណៈក្វាករបស់ហាដ្រុន(hadrons)។<br>**បំណិនសម្បទា**<br>- បង្ហាញពីដំណើរការរបស់ស៊ីក្លូត្រុង<br>- បញ្ជាក់ភាពខុសគ្នានៃស៊ីក្លូត្រុងនិងស៊ីក្លូត្រុន<br>- បង្ហាញពីភាពខុសគ្នារវាងផង់និងមិនមែនផង់<br>- កំណត់នូវគោលការណ៍គ្រឹះនៃផង់<br>- កំណត់នូវលក្ខណៈក្វាក<br>- កំណត់ចំនួនកង់ទិចពីធាតុនៃក្វាក<br>- បង្ហាញថា ប្រូតុងនិងណឺត្រុងមិនមែនជាផង់គ្រឹះទេ ព្រោះប្រូតុងនិងណឺត្រុងផ្ទុកក្វាក<br>- ពិពណ៌នាអំពីគម្រូក្វាកនៃហាដ្រុនជាអនុគមន៍នៃ អឹប (u) ដោន (d) ស្ត្រេន (s) ឆាម (c) ថប (t) បតថឹម (b) និងអង់ទីក្វាកចំនួន៦ទៀត។<br>- ពិពណ៌នានូវប្រូតុងនិងណឺត្រុងជាអនុគមន៍នឹងគម្រូក្វាក<br>- បង្ហាញថា មានអន្តរកម្មខ្សោយរវាងក្វាកនិងក្វាក ដោយការបន្សាយ $\beta$<br>- ពិពណ៌នាការបន្សាយ $\beta^-$ និង $\beta^+$ ជាអនុគមន៍នឹងគម្រូក្វាកបង្ហាញថា អេឡិចត្រុងនិងប្រូតុងជាលីបតុន។<br>**ចរិយាសម្បទា**<br>- អភិវឌ្ឍចំណេះដឹងលើការស្រាវជ្រាវផ្នែកផង់ (ក្វាក)។ | ៨ម៉ |

## ៨- ឯកសារយោង


១- គោលនយោបាយសម្រាប់អភិវឌ្ឍកម្មវិធីសិក្សាចំណោះទូទៅឆ្នាំ ២០០៥-២០០៩

២- កម្មវិធីសិក្សាគោលសម្រាប់ឲ្យមសិក្សាឆ្នាំ ១៩៩៦

៣- កម្មវិធីសិក្សាលម្អិតវិទ្យាសាស្ត្រសម្រាប់អប់រំមូលដ្ឋានចំណោះទូទៅឆ្នាំ ២០០៦

៤- ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណោះទូទៅ និងអប់រំបច្ចេកទេសឆ្នាំ ២០១៥

៥- សៀវភៅសិក្សាគោលវិទ្យាសាស្ត្រថ្នាក់ទី៧ ដល់ថ្នាក់ទី១២

៦- ស្តង់ដាកម្មវិធីសិក្សាថ្នាក់កម្រិតមូលដ្ឋាន

៧- កម្មវិធីសិក្សាប្រទេស ថៃ ម៉ាឡេស៊ី និងសឹង្ហបុរី។

៨- សៀវភៅ Serway 7&8

៩- សៀវភៅ Giancoli and Cutnell

## ៩- បញ្ជីឈ្មោះគណៈកម្មការ

### គណៈកម្មការគ្រប់គ្រង

១- ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**
២- ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន**
៣- ឯកឧត្តម **លាង សេងហាក់**
៤- ឯកឧត្តម **ពុត សាមិត្ត**
៥- លោកបណ្ឌិត **ម៉ុក សារ៉ុម**
៦- លោក **ង៉ោ ប៉េងឡុង**
៧- លោក **ផោ សៀម**

### គណៈកម្មការរៀបចំកម្មវិធីសិក្សាលម្អិត

១- លោក **ង៉ោ ប៉េងឡុង**
២- លោកបណ្ឌិត **ជ័យ ចាន់ផឿន**
៣- លោកបណ្ឌិត **ឃុន គឹមលាង**
៤- លោក **ព្រុំ វិបុល**
៥- លោក **ម៉ែន វណ្ណារី**
៦- លោក **សូ គន្ធី**
៧- លោកស្រី **សំបាត់ អ៊ាត**
៨- លោក **លាង សម្បត្តិ**
៩- លោក **ដាញ់ សុភី**
១០- លោក **ទិត្យ ប្រុស**
១១- លោក **លាង ងួនលី**
១២- លោក **អឹង ហេង**
១៣- លោក **នៃ ស៊ីណា**
១៤- លោក **ជា សុផាត**
១៥- លោក **ស៊ុយ ប៊ុនធឿន**
១៦- លោក **ឃុន សុភាព**
១៧- លោក **ខួង រតនា**
១៨- លោក **តុល បញ្ញា**
១៩- លោក **ឡុង ឃី**
២០- លោក **រៀន រិទ្ធី**

### គណៈកម្មការត្រួតពិនិត្យ

១- ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន**
២- ឯកឧត្តមបណ្ឌិតសភាចារ្យ **ច័ន្ទ សំណព្វ**
៣- ឯកឧត្តមបណ្ឌិត **ជេត ជាលី**
៤- លោកបណ្ឌិត **ម៉ុក សារ៉ុម**
៥- លោក **យិន ធី**
៦- លោក **យឹម សារិន**
៧- លោក **ស៊ុន ប៊ុណ្ណា**
៨- លោក **វ៉ា វុទ្ធី**

### លេខាធិការដ្ឋាន

១- លោកបណ្ឌិត **ម៉ុក សារ៉ុម**
២- លោកបណ្ឌិត **ជ័យ ចាន់ផឿន**
៣- លោកបណ្ឌិត **ឃុន គឹមលាង**
៤- លោកបណ្ឌិត **ម៉ម សុជាតិ**
៥- លោក **អុន ស៊ីវុធថា**
៦- លោក **យិន ធី**
៧- លោក **យឹម សារិន**
៨- លោក **ហាក់ ធម្មតា**
៩- លោកស្រី **វ៉ាន់ លីណា**

### ជំនួយការបច្ចេកទេសកុំព្យូទ័រ

១- លោក **លឹម សុត្ថារិទ្ធ**
២- លោក **អេង វណ្ណារិទ្ធ**
៣- លោក **មឿន លិនណា**
៤- លោក **ជួន ចេវ**

**ចរិយាសម្បទា**

អភិវឌ្ឍបុគ្គល គ្រួសារ និងសង្គម
សហគ្រិនភាពនិងភាពជាអ្នកដឹកនាំ
ការទទួលខុសត្រូវ
កាយសុខភាព
ចិត្តសុខភាព

**វិជ្ជាសម្បទា**

អក្ខរសាស្ត្រ
លេខសាស្ត្រ
ភាសាបរទេស
បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍

**បំណិនសម្បទា**

បំណិនពិចារណានិងការបង្កើតថ្មី
ប្រាស្រ័យទាក់ទងនិងធ្វើការងារជាក្រុម
អនុវត្តចំណេះដឹងនិងជំនាញ